សមាគមខ្មែរកញ្ញាកម្ពុជា

# ព្រឹត្តិបត្រព័ត៌មានសមាគមខ្មែរកញ្ញាកម្ពុជា

## ឆ្នាំទី២ លេខ៥ ត្រីមាសទី១ ឆ្នាំ២០២៥




ផលិតដោយៈ អគ្គលេខាធិការដ្ឋាន
សមាគមខ្មែរកញ្ញាកម្ពុជា

# មាតិកា


- អ្នកឧកញ៉ា ង៉ូវ សៀមឈុន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចូលរួមគោរពវិញ្ញាណក្ខន្ធព្រឹទ្ធមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ លឹម ព្រួញ ត្រូវជាឪពុកបង្កើតរបស់ ឧកញ៉ា លឹម ស្នេហ៍គំនិត......................................................១
- អ្នកឧកញ៉ា ហ៊ុន ឡាក់ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ជួបពិភាក្សាការងារជាមួយ ប្រតិភូពាណិជ្ជកម្មនៃការិយាល័យស្ថានទូតកាណាដាប្រចាំព្រះរាជាណាចក្រកម្ពុជា ..................................................................................២
- លោកអ្នកឧកញ៉ា លី ហួរ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ជួបពិភាក្សាការងារជាមួយឯកឧត្តម Jam Kamal Khan រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថានស្តីពី កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគ រវាងសមាគមឧកញ៉ាកម្ពុជា និងភាគីប៉ាគីស្ថាន...................................................................................៣
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ព្រមទាំងក្រុមការងារអ្នកច្បាប់ នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមកិច្ចប្រជុំណែនាំជាមួយតំណាងអន្តរក្រសួងករណីឧកញ៉ា ឆេង ស្រីរ័ត្ន...................................................................................៥
- អ្នកឧកញ៉ា សៀ ឬទ្ធី ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមអមដំណើរ **សម្តេចនាយករដ្ឋមន្ត្រី** ក្នុងដំណើរអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋហ្វីលីពីន...................................................................................៦
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ សុខ គៀង ដែលត្រូវជាម្តាយក្មេករបស់ អ្នកឧកញ៉ា អ៊ូ ឆាយ សមាជិក នៃសមាគមឧកញ៉ាកម្ពុជា...........៩
- សមាគមឧកញ៉ាកម្ពុជា ប្រារព្ធកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ ប្រចាំឆ្នាំ២០២៥ ក្រោមប្រធានបទ " ទាំងអស់គ្នាដើម្បីការអប់រំ" នៅវិទ្យាល័យទ្រៀល ខេត្តកំពង់ធំ.......................................................១០
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវ រួមជាមួយ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបទៀត អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបើកពិព័រណ៍រថយន្ត លើកទី២ ឆ្នាំ២០២៥...................................................................................១៦
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិភាក្សាការងារ និងការផ្គូផ្គងធុរកិច្ចជាមួយគណៈប្រតិភូធុរជន នៃការិយាល័យសភាពាណិជ្ជកម្មកម្ពុជាប្រចាំរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាម៉េរិក នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា...................................................................................១៧
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងសមាជិកសមាគមឧកញ៉ាកម្ពុជាជាច្រើនរូប ចូលរួមក្នុងពិធីបើកសន្និ សីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ ស្តីពី «យុទ្ធសាស្ត្រកំណើនថ្មីរបស់កម្ពុជា៖ អាទិភាពសម្រាប់ការអភិវឌ្ឍប្រកបដោយគុណភាព និងនិរន្តរភាព»...................................................................................១៩
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ រួមទាំងសមាជិកសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបបានចូលរួមក្នុង "ពិធីទទួលស្វាគមន៍ និងជំនួបផ្គូផ្គងធុរកិច្ច" រៀបចំដោយអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ...............................២១
- គណៈប្រតិភូសមាគឧកញ៉ាកម្ពុជាចូលរួមក្នុង "ជំនួបផ្គូផ្គងធុរកិច្ច និងអាហារពេលល្ងាច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល និង ឯកឧត្តម Wang Wenbin ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា...................................................................................២៣
- សមាគមឧកញ៉ាកម្ពុជា ប្រារព្ធសន្និបាតលើកទី២ ដើម្បីបូកសរុបលទ្ធផលការងារក្នុងឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ ព្រមទាំងពិធីពិសាភោជនាហារសាមគ្គី នៃគ្រួសារសមាគមឧកញ៉ាកម្ពុជា.........................................២៥

- អ្នកឧកញ៉ា ហ៊ុន ឡាក់ នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោម ជាតិស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០......................................៣៥
- អ្នកឧកញ៉ា ផៃ ហុកឈួន អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹក នាំសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបចូលរួមក្នុងពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌន នៃសាសនាឥស្លាមកម្ពុជា លើកទី៩ ឆ្នាំ២០២៥...៣៧
- សមាគមឧកញ៉ាកម្ពុជា រៀបចំពិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ ប្រចាំឆ្នាំ២០២៥ ក្រោមប្រធានបទ ទាំងអស់គ្នាដើម្បីការអប់រំ នៅសាលាចំនួន ៩ នៅក្នុងខេត្តកំពង់ធំ.................................................................៣៩
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាអញ្ជើញដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធសព ឯកឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន ដែលត្រូវជាបងប្រុសច្បងរបស់ **សម្តេចតេជោ ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា ..............................................................................................៥៨

# អ្នកឧកញ៉ា ង៉ូវ សៀមឈុន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ចូលរួមគោរពវិញ្ញាណក្ខន្ធព្រឹទ្ធមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ លឹម ព្រួញ ត្រូវជាឪពុករបស់ ឧកញ៉ា លឹម ស្នេហ៍គំនិត សមាជិក នៃសមាគមឧកញ៉ាកម្ពុជា

នារសៀលថ្ងៃអង្គារ ១រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៥ អ្នកឧកញ៉ា ង៉ូវ សៀមឈុន សមាជិក នៃសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវ បាននាំយកនូវលិខិតរំលែកមរណទុក្ខក៏ដូចជាបច្ច័យពីសមាគមឧកញ៉ាកម្ពុជា ជូនចំពោះ ឧកញ៉ា លឹម ស្នេហ៍គំនិត និងក្រុមគ្រួសារដែលកំពុងមានទុក្ខជាទម្ងន់ដោយ ព្រឹទ្ធមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ លឹម ព្រួញ ដែលត្រូវជាឪពុកបង្កើត ឪពុកក្មេក និងជីតា បានទទួលមរណភាពកាលពីថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែមករា ឆ្នាំ២០២៥ កន្លងទៅក្នុងជន្មាយុ ៧៨ឆ្នាំដោយរោគាពាធ ខណៈដែលពិធីបុណ្យត្រូវបានប្រារព្ធឡើងនាគេហដ្ឋានរបស់សពដែលស្ថិតនៅក្នុងខេត្តសៀមរាប។

ក្នុងវេលាប្រកបដោយទុក្ខសោកនេះ អ្នកឧកញ៉ា ង៉ូវ សៀមឈុន បានពាំនាំនូវសារចូលរួមរំលែកមរណទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ជូនចំពោះក្រុមគ្រួសារនៃសពដែលបានបាត់បង់ឪពុកបង្កើត ឪពុកក្មេក និងជីតា ជាទីគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅនិងពោរពេញទៅដោយព្រហ្មវិហារធម៌មួយរូប។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធព្រឹទ្ធមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ លឹម ព្រួញ សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។







# អ្នកឧកញ៉ា ហ៊ុន ឡាក់ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាជួបពិភាក្សាការងារជាមួយ លោក ដេវីដ វីប្បូសស្តី ភារធារី និងលោក ម៉ែន ប៊ុនឡេង ប្រតិភូពាណិជ្ជកម្មនៃការិយាល័យស្ថានទូតកាណាដាប្រចាំព្រះរាជាណាចក្រកម្ពុជា







នាថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានជួបពិភាក្សាការងារជាមួយលោក ដេវីដ វីប្បូសស្តី ជាភារធារី និងលោកម៉ែន ប៊ុនឡេង ជាប្រតិភូពាណិជ្ជកម្មនៃការិយាល័យស្ថានទូតកាណាដាប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្នាក់ការសមាគមឧកញ៉ាកម្ពុជា។ ជំនួបនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័នទាំងពីរក៏ដូចជាពិភាក្សាលើកិច្ចសហការក្នុងការត្រៀមរៀបចំទទួលប្រតិភូធុរកិច្ចកាណាដាដែលគ្រោងនឹងបំពេញទស្សនកិច្ចមកកាន់ព្រះរាជាណាចក្រកម្ពុជានាថ្ងៃទី២៩-៣០ ខែឧសភា ឆ្នាំ២០២៥ ខាងមុខនេះ។

អ្នកឧកញ៉ាអគ្គលេខាធិការ បានសម្តែងការស្វាគមន៍ចំពោះលោកភារធារី និងលោកប្រតិភូពាណិជ្ជកម្ម និងបានជម្រាបជូនអំពីចក្ខុវិស័យ បេសកកម្ម ព្រមទាំងសកម្មភាពសំខាន់ៗរបស់សមាគមដែលជាដៃគូមួយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញលើកកម្ពស់សេដ្ឋកិច្ច សកម្មភាពពាណិជ្ជកម្មនិងការវិនិយោគ និងសកម្មភាពផ្សេងៗទៀតដើម្បីជាឧត្តមប្រយោជន៍សង្គមជាតិ។ លើសពីនេះ អ្នកឧកញ៉ា ក៏បានជម្រាបជូនអំពីបេសកកម្មជំរុញនិងទាក់ទាញវិនិយោគដឹកនាំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទៅកាន់បណ្តាប្រទេសនានាដែលប្រតិភូសមាគមបានចូលរួមនាពេលកន្លងមក ក្នុងនោះក៏មានទស្សនកិច្ចទៅកាន់ប្រទេសកាណាដាផងដែរដោយទទួលបានជោគជ័យ និងលទ្ធផលផ្លែផ្កាជាវិជ្ជមាន។

លោក ភារធារី បានវាយតម្លៃខ្ពស់នូវតួនាទីដ៏សំខាន់របស់សមាគមដែលជាបណ្តុំនៃធុរជន និងវិនិយោគិនមកពីពហុវិស័យ និងជាកម្លាំងចលករមួយរួមចំណែកដល់ការជំរុញសកម្មភាពពាណិជ្ជកម្ម និងកំណើនសេដ្ឋកិច្ចជាតិ។ ក្នុងជំនួបនេះដែរលោក ភារធារី បានជម្រាបជូនអំពីគម្រោងដឹកនាំប្រតិភូធុរកិច្ចកាណាដាប្រមាណ ៨០ក្រុមហ៊ុនដែលមានបំណងស្វែងរកដៃគូ និងដាក់ទុនវិនិយោគនៅកម្ពុជា និងបានស្នើសុំការគាំទ្រ និងកិច្ចសហការពីសមាគមឧកញ៉ាកម្ពុជា ក្នុងការរៀបចំព្រឹត្តិការណ៍ធុរកិច្ចនានាដើម្បីផ្តល់នូវឱកាសធុរកិច្ចដល់ធុរជននៃប្រទេសទាំងពីរធ្វើការតភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមក។

យោងតាមលទ្ធផលនៃជំនួបនេះ ស្ថាប័នទាំងពីរបានបង្ហាញក្តីរីករាយក្នុងការផ្តល់កិច្ចសហការ និងការគាំទ្រលើការរៀបចំឱ្យមានព្រឹត្តិការណ៍ធុរកិច្ចជាមួយគ្នា និងរៀបចំជាក្រុមការងារសម្រាប់ជាយន្តការសម្របសម្រួលការងារនេះឱ្យបានជោគជ័យផងដែរ។

# លោកអ្នកឧកញ៉ា លី ហួរ ជួបពិភាក្សាការងារ ជាមួយ ឯកឧត្តម Jam Kamal Khan រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគ

នាថ្ងៃចន្ទ ៧រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែមករា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី ហួរ អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំអ្នកឧកញ៉ា ឧកញ៉ា សមាជិកក្រុមប្រឹក្សាភិបាល ក៏ដូចជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាស្តីពី កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគ ជាមួយឯកឧត្តម Jam Kamal Khan រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថាន អមដោយវត្តមានរបស់ឯកឧត្តម Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអ៊ិស្លាមប៉ាគីស្ថានប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលោក លោកស្រី ជាមន្ត្រីជាន់ខ្ពស់ជាច្រើនរូបទៀត។

ជាកិច្ចចាប់ផ្តើម លោកអ្នកឧកញ៉ាបានសម្តែងកិច្ចស្វាគមន៍ចំពោះ ឯកឧត្តមរដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរដ្ឋទូត ព្រមទាំងប្រតិភូអមទាំងអស់ដែលបានមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា ជាពិសេស បានចំណាយពេលវេលាដ៏មានតម្លៃមកកាន់ទីស្នាក់ការសមាគមឧកញ៉ាកម្ពុជាក្នុងគោលបំណងកសាងទំនាក់ទំនងល្អ និងស្វែងយល់អំពីបរិយាកាសធុរកិច្ច និងវិនិយោគនៅកម្ពុជា ក៏ដូចជាចែករំលែកអំពីវិស័យអាទិភាព និងសក្តានុពលវិនិយោគនៅប៉ាគីស្ថានផងដែរ។ លោកអ្នកឧកញ៉ាបានថ្លែងថា ជំនួបដ៏មានសារៈសំខាន់នាថ្ងៃនេះ គឺជាជំហាននៃកិច្ចចាប់ផ្តើម ក្នុងការកសាងទំនាក់ទំនងជាមួយគ្នា ខណៈដែលសមាគមឧកញ៉ាកម្ពុជាមានសមាជិកសុទ្ធសឹងតែជាពាណិជ្ជករ និងវិនិយោគិនមានសក្តានុពល និងកាន់កាប់អាជីវកម្មលើពហុវិស័យ។ លោកអ្នកឧកញ៉ា មើលឃើញនូវឱកាស និងមានសុទិដ្ឋិនិយមខ្ពស់ដែលធុរជនក៏ដូចជាវិនិយោគិន នៃប្រទេសទាំងពីរអាចចាប់ដៃគូធុរកិច្ច និងកសាងកិច្ចសហប្រតិបត្តិការជាមួយគ្នាក្នុងវិស័យអាទិភាពជាច្រើនដែលកំពុងតែមានសក្តានុពល។













ជាកិច្ចឆ្លើយតប ឯកឧត្តមរដ្ឋមន្ត្រី បានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជា ដែលបានទទួលស្វាគមន៍ឯកឧត្តមនិងប្រតិភូប៉ាគីស្ថានយ៉ាងកក់ក្តៅ។ ឯកឧត្តមបានបង្ហាញក្តីរីករាយដែលបានមកបំពេញទស្សនកិច្ចនៅកម្ពុជាដោយបានឃើញផ្ទាល់នូវភាពរីកចម្រើន វិបុលភាព និងការអភិវឌ្ឍនៅកម្ពុជាដែលពិតជាធ្វើឱ្យរូបលោកមានភាពស្ញប់ស្ញែងក្រៃលែង។ ឯកឧត្តមក៏បានជម្រាបជូនអំពីមូលហេតុចម្បងនៃដំណើរបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជានាពេលនេះដែលផ្តើមចេញពីគំនិតផ្តួចផ្តើមរវាងរដ្ឋាភិបាលប៉ាគីស្ថាន និងកម្ពុជាក្នុងការរៀបចំឱ្យមានយន្តការលើកកម្ពស់សេដ្ឋកិច្ច និងជំរុញការផ្លាស់ប្តូរសកម្មភាពពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ។ ក្នុងន័យនេះ ឯកឧត្តមរដ្ឋមន្ត្រីបានលើកទឹកចិត្តឱ្យធុរជននៃប្រទេសទាំងពីរស្វែងយល់អំពីបរិយាកាសធុរកិច្ច និងវិនិយោគឱ្យបានកាន់តែទូលំទូលាយដើម្បីចាប់ឱកាសវិនិយោគក្នុងវិស័យអាទិភាពនានាក្នុងប្រទេសទាំងពីរ ខណៈដែលនៅអំឡុងខែកុម្ភៈខាងមុខនេះនឹងមានការរៀបចំពិព័រណ៌ពាណិជ្ជកម្មក្នុងប្រទេសប៉ាគីស្ថានដែលជាឱកាសមួយសម្រាប់វិនិយោគិនកម្ពុជាអាចចូលរួមបំពេញទស្សនកិច្ចដើម្បីស្វែងយល់ព្រមទាំងទទួលបានព័ត៌មានបន្ថែមទៀត។ លើសពីនេះ ឯកឧត្តមរដ្ឋមន្ត្រីក៏បានលើកជាគំនិតឱ្យមានការចុះអនុស្សរណៈយោគយល់គ្នារវាងសមាគមឧកញ៉ាកម្ពុជា និងស្ថាប័នតំណាងសហគមន៍ពាណិជ្ជកម្មណាមួយដែលស័ក្តិសមនៅប៉ាគីស្ថានដើម្បីជំរុញទំនាក់ទំនងលើសកម្មភាពពាណិជ្ជកម្ម និងវិនិយោគរវាងវិស័យឯកជននៃប្រទេសទាំងពីរឱ្យកាន់តែសកម្ម និងប្រសើរឡើង។

ក្រោយជំនួបសម្តែងការគួរសមនេះភាគីទាំងពីរបានពិភាក្សានិងផ្លាស់ប្តូរមតិយោបល់គ្នាលើកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគដោយក្នុងនោះសម្រេចបានលទ្ធផលដូចជា៖

១,ភាគីទាំងពីរនឹងបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគរវាងវិស័យឯកជននៃប្រទេសទាំងពីរ

២,ភាគីទាំងពីរបានព្រមព្រៀងលើការរៀបចំឱ្យមានការចុះអនុស្សរណៈយោគយល់ស្តីពីការលើកកម្ពស់សកម្មភាពពាណិជ្ជកម្ម និងវិនិយោគរវាងវិស័យឯកជននៃប្រទេសទាំងពីរឱ្យកាន់តែសកម្ម និងប្រសើរឡើង

៣,ឯកឧត្តមរដ្ឋមន្ត្រីនឹងពាំនាំផ្សព្វផ្សាយអំពីវិបុលភាព ការអភិវឌ្ឍ បរិយាកាសធុរកិច្ចនិងវិនិយោគនៅកម្ពុជាទៅកាន់សហគមន៍ធុរកិច្ចប៉ាគីស្ថាន និងលើកទឹកចិត្តធុរជនប៉ាគីស្ថានសិក្សាស្វែងយល់ និងវិនិយោគនៅកម្ពុជា

៤,សមាគមឧកញ៉ាកម្ពុជានឹងពិនិត្យលទ្ធភាពលើការរៀបចំប្រតិភូចូលរួមពិព័រណ៍ ក៏ដូចជាបំពេញទស្សនកិច្ចធុរកិច្ចនៅប៉ាគីស្ថាននាពេលខាងមុខ។

# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការព្រមទាំងក្រុមការងារអ្នកច្បាប់ នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមកិច្ចប្រជុំណែនាំជាមួយតំណាងអន្តរក្រសួងករណីឧកញ៉ា ឆេង ស្រីរ័ត្ន

នាព្រឹកថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ រួមជាមួយមេធាវីដែលជាសមាជិកក្រុមការងារអ្នកច្បាប់ នៃសមាគមឧកញ៉ាកម្ពុជា បានចូលរួមក្នុងកិច្ចប្រជុំណែនាំករណីឧកញ៉ា ឆេង ស្រីរ័ត្ន ដែលបានរៀបចំឡើងនៅទីស្តីការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងដោយមានការចូលរួមពីសំណាក់តំណាងស្ថាប័នពាក់ព័ន្ធដើម្បីធ្វើការអប់រំណែនាំ និងពន្យល់អំពីគុណតម្លៃ កិត្តិយស សីលធម៌ សុជីវធម៌ និងសេចក្តីថ្លៃថ្នូរ នៃគោរមងារឧកញ៉ា ព្រមទាំងផលប៉ះពាល់ជាអវិជ្ជមានចំពោះសង្គម និងសណ្តាប់ធ្នាប់ដែលកើតចេញពីទង្វើរបស់គោរមវន្តផងដែរ។

តាមរយៈកិច្ចប្រជុំនេះ ឧកញ៉ា ឆេង ស្រីរ័ត្ន បានសន្យាចំពោះមុខតំណាងសមាគមឧកញ៉ាកម្ពុជាចំនួន ៥ចំនុចដូចខាងក្រោម៖

១.បញ្ឈប់សកម្មភាពទាំងឡាយក្រោមទម្រង់ការថតសម្តែង ការស្លៀកពាក់ ការប្រើប្រាស់ពាក្យសម្តីមិនសមរម្យ ដែលខុសឆ្គង និងបង្កផលប៉ះពាល់ដល់វប្បធម៌ ប្រពៃណី ជំនឿ សាសនា របស់ជាតិ ព្រមទាំងកិត្តិយស និងសេចក្តីថ្លៃថ្នូរ នៃគោរមងារឧកញ៉ា

២.យល់ព្រមលុបចោលនូវរូបភាពនិងវីដេអូទាំងឡាយដែលជាសកម្មភាពខុសឆ្គងដែលបានបង្ហោះកន្លងមកនិងទទួលការរិះគន់ពីសាធារណជន ជាពិសេសឃ្លីបវីដេអូ ការអត្ថាធិប្បាយទាំងឡាយដែលប៉ះពាល់សីលធម៌ និងកិត្តិយសដល់គោរមងារឧកញ៉ា

៣. យល់ព្រមទទួលយកមតិយោបល់អង្គប្រជុំពាក់ព័ន្ធនឹងទម្រង់សម្លៀកបំពាក់ និងពាក្យសម្តីមិនសមរម្យនៅក្នុងការថតផ្សាយជាសាធារណៈក្នុងគោលបំណងជៀសវាងផលប៉ះពាល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី

៤.យល់ព្រមធ្វើឃ្លីបវីដេអូផ្សព្វផ្សាយជាសាធារណៈមួយថ្ងៃបន្ទាប់ពីបានធ្វើកិច្ចសន្យានេះដោយបញ្ជាក់ពីការទទួលស្គាល់កំហុសឆ្គងប៉ះពាល់ដល់ប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា សេចក្តីថ្លៃថ្នូរ និងការសន្យាមិនឱ្យមានសកម្មភាពបែបនេះតទៅថ្ងៃមុខទៀត។











# អ្នកឧកញ៉ា សៀ ឬទ្ធី ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរ សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងដំណើរបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋហ្វីលីពីន នាថ្ងៃទី១០-១១ ខែកុម្ភៈ ឆ្នាំ២០២៥

ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា ធ្វើជាតំណាងដើម្បីដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលរួមមានសមាសភាពដូចជា អ្នកឧកញ៉ា ហ៊ុន ឡាក់, អ្នកឧកញ៉ា គួន ធីតា, អ្នកឧកញ៉ា ទី គឹមស្រ៊ាន, ឧកញ៉ា កង លាប, ឧកញ៉ា សូ សុខប៊ុនលីម, អ្នកឧកញ៉ា អ៊ឹង លីហេង, អ្នកឧកញ៉ា ទៀ ណារ៉ាវុទ្ធ, ឧកញ៉ា ប៉ោ ឌី, ឧកញ៉ាបណ្ឌិត លី រិទ្ធ, ឧកញ៉ា ឡាយ ឈុនហួ, ឧកញ៉ា ម៉ៅ បញ្ញពណ៌, លោក ធន់ សុរិសិទ្ធ, លោកស្រី ហ៊ីម លីនដា, និងលោក ទា ធារី ចូលរួមអមដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ទៅកាន់សាធារណរដ្ឋហ្វីលីពីន នាថ្ងៃទី១០-១១ ខែកុម្ភៈ ឆ្នាំ២០២៥ ប្រកបដោយភាពជោគជ័យ និងសម្រេចបានលទ្ធផលវិជ្ជមានដ៏ត្រចះត្រចង់។

ក្នុងដំណើរទស្សនកិច្ចនេះ ប្រតិភូសមាគមឧកញ៉ាកម្ពុជា បានចូលរួមកិច្ចប្រជុំសំខាន់ៗ និងព្រឹត្តិការណ៍ធុរកិច្ចជាច្រើនរួមមាន៖ ១.វេទិកាធុរកិច្ចកម្ពុជា-ហ្វីលីពីន, ២.ជំនួបសម្តែងការគួរសមជាមួយ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**, ៣.ជំនួបអាហារពេលព្រឹកក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល ជាមួយគណៈប្រតិភូធុរជនកម្ពុជា-ហ្វីលីពីន, និង ៤កិច្ចប្រជុំពិភាក្សារវាងសមាជិកប្រតិភូសមាគមឧកញ៉ាកម្ពុជាដើម្បីចែករំលែកក៏ដូចជាការផ្តល់ធាតុចូលលើបទពិសោធន៍ធុរកិច្ច និងអត្ថប្រយោជន៍នានាដែលទទួលបានក្នុងអំឡុងពេលបំពេញទស្សនកិច្ចនេះ។














## សម្តេចមហាបវរធិបតី អនុញ្ញាតឱ្យ អ្នកឧកញ៉ា ហ៊ុន ឡាក់ និងលោក Dai Jianlaing ប្រធានក្រុមហ៊ុន Excellent Associates Group Limited ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៥ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យអ្នកឧកញ៉ា ហ៊ុន ឡាក់រួមជាមួយប្រតិភូធុរជនហ្វីលីពីនរួមមានលោក Dai Jianlaing ប្រធានក្រុមហ៊ុន Excellent Associates Group Limited និងសហការីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារក្នុងឱកាសនៃដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។

ជំនួបដ៏មានសារៈសំខាន់នេះ លោក Dai Jianlaing បានគោរពជម្រាបជូន **សម្តេចធិបតី** អំពីប្រតិបត្តិការ និងវឌ្ឍនភាពរបស់ក្រុមហ៊ុន និងបានបង្ហាញពីចំណាប់អារម្មណ៍ស្វែងរកឱកាសវិនិយោគនៅកម្ពុជា ដែលរួមមានការវិនិយោគស្ពូនឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម ព្រមទាំងការកែច្នៃ និងនាំចេញអង្ករទៅកាន់ទីផ្សារសំខាន់ៗមួយចំនួនដូចជា ហុងកុងប្រទេសចិន និងទីផ្សារដទៃទៀតនាពេលអនាគតព្រោះតែអង្ករកម្ពុជាមានគុណភាពខ្ពស់ និងទទួលបានចំណាត់ថ្នាក់ល្អច្រើនឆ្នាំជាប់ៗគ្នា។

ជាការឆ្លើយតប **សម្តេចធិបតី** បានបង្ហាញក្តីសោមនស្សចំពោះចំណាប់អារម្មណ៍របស់ក្រុមហ៊ុនក្នុងការស្វែងរកឱកាសវិនិយោគ នៅកម្ពុជា។ **សម្តេច** ក៏បានបញ្ជាក់អំពីការដាក់ចេញនូវគោលនយោបាយ និងវិធានការរបស់រាជរដ្ឋាភិបាលក្នុងការគាំទ្រដល់ការរៀបចំបង្កើតតំបន់សេដ្ឋកិច្ចពិសេស។ ជាមួយគ្នានេះ ពាក់ព័ន្ធនឹងវិស័យកសិ-ឧស្សាហកម្ម **សម្តេច** បានលើកទឹកចិត្តឱ្យក្រុមហ៊ុនពិចារណាការវិនិយោគលើទំនិញកសិ-ឧស្សាហកម្មមួយចំនួនបន្ថែមទៀតដែលអាចចូលរួមបំពេញតម្រូវការក្នុងច្រវាក់ផលិតកម្មនៃវិស័យកសិកម្មក៏ដូចជាការ ផលិតជីបែបធម្មជាតិ និងជីគីមីជាដើម។







## គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមកិច្ចប្រជុំអាហារពេលព្រឹករវាងថ្នាក់ដឹកនាំធុរកិច្ចល្បីៗមកពី សហគមន៍ធុរកិច្ចហ្វីលីពីន និងកម្ពុជាក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល

នាព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៥ អ្នកឧកញ៉ា សៀ ឫទ្ធី បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងកិច្ចប្រជុំអាហារពេលព្រឹករវាងថ្នាក់ដឹកនាំធុរកិច្ចល្បីៗមកពីសហគមន៍ធុរកិច្ចហ្វីលីពីន និងកម្ពុជាដោយផ្តោតលើការស្វែងយល់ពីឱកាសអាជីវកម្ម និងការពង្រឹងទំនាក់ទំនងរវាងប្រជាជាតិទាំងពីរ ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ក្នុងឱកាសនេះដែរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍គូសបញ្ជាក់អំពីគន្លងកំណើនជាវិជ្ជមាននៃផែនការដ៏ទូលំទូលាយផ្នែកព័ស្តុភាររបស់ប្រទេសកម្ពុជាដោយបានលើកឡើងពីស្ថិរភាពនយោបាយរបស់ប្រទេស និងភាពងាយស្រួលនៃការវិនិយោគបរទេសដែលជាកត្តាគន្លឹះក្នុងការធ្វើអាជីវកម្មនៅកម្ពុជា។

ជាមួយគ្នានេះ អ្នកឧកញ៉ា សៀ ឫទ្ធី បានចែករំលែកអំពីទស្សនវិស័យ បេសកកម្ម និងតួនាទីស្នូលរបស់សមាគមឧកញ៉ាកម្ពុជាដែលជាសមាគមតែមួយគត់នៅកម្ពុជា ប្រមូលផ្តុំនូវធុរជននិងវិនិយោគិនមកពីចម្រុះវិស័យ និងត្រៀមខ្លួនក្នុងកិច្ចសហប្រតិបត្តិការធុរកិច្ចផងដែរ។ លើសពីនេះ អ្នកឧកញ៉ា បានពន្យល់លម្អិតអំពីសក្តានុពលរបស់កម្ពុជាក្នុងការធ្វើជាមជ្ឈមណ្ឌលដឹកជញ្ជូន និងពិភាក្សាអំពីឱកាសដ៏ជោគជ័យក្នុងការផលិត និងកែច្នៃម្ហូបអាហារ ព្រមទាំងលើកទឹកចិត្តធុរជនហ្វីលីពីនមកសិក្សាស្វែងយល់ទីផ្សារនៅកម្ពុជា និងបង្កើតភាពជាដៃគូដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក។ ប្រធានបទដ៏សំខាន់មួយដែរនោះ អ្នកឧកញ៉ា បានគូសបញ្ជាក់អំពីបរិមាណអាហារឆៅដ៏ច្រើនដែលត្រូវបាននាំចេញទៅកាន់ប្រទេសជិតខាងជំនួសឱ្យការកែច្នៃក្នុងស្រុកដែលនេះគឺជាកាលានុវត្តភាពសម្រាប់វិនិយោគិនផ្នែកកែច្នៃម្ហូបអាហារដើម្បីពិចារណាពីឱកាសទីផ្សារនៅកម្ពុជា។ អ្នកឧកញ៉ា ក៏បានលើកឡើងពីការពិតដែលថាប្រទេសហ្វីលីពីន មានភាពខ្លាំងខាងផ្នែកអេឡិចត្រូនិក ជាពិសេសសម្រាប់ការនាំចេញ និងការជំរុញការផលិតក្នុងស្រុកបន្ថែមទៀតនៅក្នុងវិស័យរថយន្តអេឡិចត្រូនិកដែលនឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់តំបន់អាស៊ានទាំងមូល។ ទន្ទឹមនឹងនេះ អ្នកឧកញ៉ា បានអញ្ជើញថ្នាក់ដឹកនាំធុរកិច្ចហ្វីលីពីនមកស្វែងយល់ទីផ្សារកម្ពុជា និង បង្កើតភាពជាដៃគូដែលមានផលប្រយោជន៍ទៅវិញទៅមក។

សូមបញ្ជាក់ថា សមាសភាពសំខាន់ៗដែលបានចូលរួមនៅក្នុងកិច្ចប្រជុំអាហារពេលព្រឹកនេះរួមមាន លោកជំទាវ Flerida Ann Camille P. Mayo ឯកអគ្គរដ្ឋទូតប្រទេសហ្វីលីពីនប្រចាំនៅកម្ពុជារួមទាំងនាយកប្រតិបត្តិជាន់ខ្ពស់មកពីសាជីវកម្មហ្វីលីពីនធំៗដូចជា SM Investments Corp, Ayala, Aboitiz Group, Megawide, Mercury Drug, Airspeed, Century Pacific Food, Philippine Airlines, ECPay, Destileria Limtuac, ថ្នាក់ដឹកនាំជាន់ខ្ពស់នៃឧស្សាហកម្មហ្វីលីពីន និងក្រុមហ៊ុន Chamber CI Limtuaco ជាដើម។ ជំនួបនេះ គឺជាជំហានដ៏សំខាន់មួយក្នុងការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពង្រឹងទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីរវាងហ្វីលីពីន និងកម្ពុជា។











# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធ មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ សុខ គៀង ដែលត្រូវជាម្តាយក្មេករបស់អ្នកឧកញ៉ា អ៊ូ ឆាយ សមាជិក នៃសមាគមឧកញ៉ាកម្ពុជា

នាថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ សុខ គៀង ដែលត្រូវជាម្តាយក្មេករបស់ អ្នកឧកញ៉ា អ៊ូ ឆាយ សមាជិក នៃសមាគមឧកញ៉ាកម្ពុជា។

នៅក្នុងឱកាសពោរពេញដោយក្តីក្រៀមក្រំនេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ បាននាំយកនូវសាររំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ជូនចំពោះ អ្នកឧកញ៉ា អ៊ូ ឆាយ និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារដែលកំពុងមានទុក្ខជាទម្ងន់ដោយមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ សុខ គៀង ដែលត្រូវជាម្តាយបង្កើត ម្តាយក្មេក ជីដូន ជីដូនទួត បានទទួលមរណភាពកាលពីវេលាម៉ោង ១.២៥នាទី រំលងអធ្រាត្រ ថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៥ ក្នុងជន្មាយុ ៨៧ឆ្នាំដោយជរាពាធ។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ សុខ គៀង សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។













# សមាគមឧកញ៉ាកម្ពុជា ប្រារព្ធកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ ប្រចាំឆ្នាំ២០២៥ ក្រោមប្រធានបទ "ទាំងអស់គ្នាដើម្បីការអប់រំ" នៅវិទ្យាល័យទ្រៀល ស្ថិតក្នុងភូមិថ្មី ឃុំទ្រៀល ស្រុកតាំងគោក ខេត្តកំពង់ធំ

នាថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥ ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រី ប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ រួមជាមួយលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវបានអញ្ជើញជាគណៈអធិបតីក្នុងកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ ប្រចាំឆ្នាំ២០២៥ ក្រោមប្រធានបទ " ទាំងអស់គ្នាដើម្បីការអប់រំ" នៅវិទ្យាល័យ ទ្រៀល ស្ថិតក្នុងភូមិថ្មី ឃុំទ្រៀល ស្រុកតាំងគោក ខេត្តកំពង់ធំដោយមានការចូលរួមពីសំណាក់មន្ត្រីរាជការ អាជ្ញាធរដែនដី លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សប្រមាណជិត ៣ពាន់នាក់។

នាក្នុងឱកាសនោះដែរ ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ធំ បានមានប្រសាសន៍ថា អំណោយសប្បុរសធម៌របស់សមាគមឧកញ៉ាកម្ពុជាដែលសរុបទឹកប្រាក់ជាង ១,១លានដុល្លារអាមេរិក នាពេលនេះគឺមានតម្លៃខ្លាំងណាស់សម្រាប់រាជរដ្ឋាភិបាលនិយាយជារួម និងនិយាយដោយឡែកសម្រាប់ខេត្តកំពង់ធំ និងប្រជាពលរដ្ឋក្នុងខេត្តកំពង់ធំផ្ទាល់តែម្តង។










ជាមួយគ្នានេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានរំលឹកពីគំនិតគាំទ្រដ៏ថ្លៃថ្លាប្រកបទៅដោយចក្ខុវិស័យ វែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាចំពោះការបង្កើតនិងកិច្ចដំណើរការដ៏មានសារៈសំខាន់ នៃសមាគមឧកញ៉ាកម្ពុជា។ ជាមួយនឹងចក្ខុវិស័យនេះ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលមាន **សម្តេចធិបតី ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រី ក៏នៅតែចាត់ទុកវិស័យឯកជន ជាដៃគូសំខាន់បំផុត និងរួមចំណែកជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ការបង្កើតការងារ បង្កើនប្រាក់ចំណូល និងតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច, ចូលរួមចំណែកក្នុងសកម្មភាពសង្គម មនុស្សធម៌ និងសប្បុរសធម៌ ជាពិសេសក្នុងការកសាងធនធានមនុស្ស និងលើកតម្កើងគុណតម្លៃរបស់ «ឧកញ៉ា» ទាំងតម្លៃសីលធម៌ ចរិយាធម៌ និងគុណធម៌ ឱ្យស័ក្តិសមនឹងឋានៈក្នុងសង្គម សំដៅចូលរួមកសាង និងអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ប្រកបដោយបរិយាបន្ន និងចីរភាព។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ក៏ដូចជា លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាអនុប្រធាន និងសមាជិកសមាជិកាសមាគម ព្រមទាំងសប្បុរសជនចំនួន១១៤រូប ដែលបានចូលរួមបរិច្ចាគជាថវិកានិងសម្ភារៈសរុបជាទឹកប្រាក់ជាង ១,១៧៨,៨៨៨ ដុល្លារអាមេរិក សម្រាប់ប្រគល់ជូន លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៃខេត្តកំពង់ធំក្នុងនោះរួមមាន៖ កសាងអគារសិក្សាចំនួន៥ខ្នង ស្មើនឹង៥៥បន្ទប់, ថវិកាសម្រាប់ជួសជុលអគារសិក្សា កសាងហេដ្ឋារចនាសម្ព័ន្ធ ក្តារខៀន តុ កៅអី និងសម្ភារៈការិយាល័យក្នុងសាលាទាំង១០ ថវិកាលើកទឹកចិត្ត សម្ភារៈសិក្សា និងសម្លៀកបំពាក់ សម្រាប់លោកគ្រូអ្នកគ្រូចំនួន ១៨៥នាក់ និងសិស្សានុសិស្សសរុប ៥៦៥០នាក់ ក៏ដូចជា មធ្យោបាយធ្វើដំណើររួមមានម៉ូតូ ១៥គ្រឿង និងកង់ ១៦គ្រឿង សម្រាប់លោកគ្រូអ្នកគ្រូដែលមានទីលំនៅឆ្ងាយពីសាលារៀន ព្រមទាំងកង់ ៧៨៤គ្រឿងដល់សិស្សានុសិស្សដែលមានជីវភាពលំបាក និងខ្វះខាតមធ្យោបាយធ្វើដំណើរផងដែរ។

ជាមួយគ្នានេះលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានមានប្រសាសន៍ថាសមាគមឧកញ៉ាកម្ពុជាបានចាត់ទុកការចូលរួមសកម្មភាពសប្បុរសធម៌ និងសង្គមកិច្ច គឺជាការងារអាទិភាពមួយរបស់ខ្លួនដែលបានចូលរួម និងគាំទ្រយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុត និងប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃរបស់ **សម្តេចតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានកិត្តិយសសមាគមឧកញ៉ាកម្ពុជា ដែលជាអគ្គស្ថាបនិកដ៏ឆ្នើម នៃគោលនយោបាយ ឈ្នះ ឈ្នះ បាននាំមកនូវការបង្រួបបង្រួមជាតិ ឯកភាពទឹកដី និងការអភិវឌ្ឍជាតិ នាពេលបច្ចុប្បន្ននេះ ដែលកំពុងបន្តអនុវត្តយ៉ាងស្វាហាប់ និងឈ្លាសវៃ តាមមាគ៌ាដ៏ត្រឹមត្រូវដោយយុវជនបន្តវេនដ៏ប៉ិនប្រសប់របស់យើងគឺ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។















លោកអ្នកឧកញ៉ា ក៏បានផ្តាំផ្ញើ និងក្រើនរំលឹកដល់ក្មួយៗសិស្សានុសិស្ស ទាំងអស់ឱ្យខិតខំប្រឹងប្រែងរៀនសូត្រឱ្យបានខ្លាំងក្លាជាទីបំផុតដើម្បីអនាគតភ្លឺស្វាង សម្រាប់ខ្លួនឯង គ្រួសារនិងសង្គមជាតិ ពោលគឺជាសិស្សល្អ ពលរដ្ឋល្អ យុវជនល្អ និងមានសុខភាពល្អដែលជាធនធានមនុស្សដ៏មានគុណតម្លៃ ជាពិសេសត្រូវជៀស ឱ្យឆ្ងាយពីគ្រឿងញៀន និងអំពើអបាយមុខទាំងអស់ដើម្បីក្លាយជាយុវជនបន្តវេន ប្រកបដោយថាមពលក្នុងការចូលរួមថែរក្សាឱ្យខាងតែបាននូវសុខសន្តិភាព និងការ ឯកភាពជាតិដែល **សម្តេចតេជោ** បានលះបង់សាច់ស្រស់ឈាមស្រស់ដើម្បី ស្វែងរក និងបន្សល់ទុកឱ្យ និងបន្តគាំទ្រលើការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា បច្ចុប្បន្នដែលមាន **សម្តេចធិបតី** ជាអ្នកដឹកនាំបន្តវេនដ៏ឆ្នើមដើម្បីកាច់ចង្កូតនាវាកម្ពុជាឆ្ពោះទៅកាន់គោលដៅជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

គួររំលឹកថា នាពេលកន្លងទៅសមាគមឧកញ៉ាកម្ពុជា បានទទួលសំណើមួយពី ឯកឧត្តម នួន ផារ័ត្ន អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ តាមរយៈ ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ធំ ដើម្បីសុំជួយជួសជុល និងកសាងអគារសិក្សា ព្រមទាំងឧបត្ថម្ភដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សដែលកំពុងជួបការលំបាក និងខ្វះខាត នៅតាមគ្រឹះស្ថានសិក្សាសាធារណៈក្នុងខេត្តកំពង់ធំ។ បន្ទាប់ពីបានទទួលសំណើខាងលើនេះហើយ សមាគមឧកញ៉ាកម្ពុជា បានចាត់ក្រុមការងារជាបន្ទាន់ដើម្បីចុះមកពិនិត្យនៅទីតាំងជាក់ស្តែងដែលជាលទ្ធផល គឺឃើញថា មានសាលាចំនួន១០ទីតាំងផ្សេងគ្នាកំពុងត្រូវការអគារសិក្សា និងមានការខ្វះខាតដែលត្រូវការជំនួយជាបន្ទាន់។

ដោយមើលឃើញពីតម្រូវការខាងលើនេះ សមាគមឧកញ៉ាកម្ពុជា បានកៀរគរសប្បុរសជននានា ដែលជាសមាជិករបស់សមាគមចូលរួមបរិច្ចាគថវិកា និងសម្ភារៈតាមលទ្ធភាព និងធនធានដែលមានសប្បុរសជន ១១៤នាក់ បានបរិច្ចាគជាថវិកាសរុបចំនួន ១,០៣០,០០០ ដុល្លារអាមេរិក និងសម្ភារៈមួយចំនួន ដែលគិតជាទឹកប្រាក់សរុបចំនួន ១៤៨,៨៨៨ ដុល្លារអាមេរិក ដូចនេះ សរុបទាំងអស់ស្មើនឹង ១,១៧៨,៨៨៨ ដុល្លារអាមេរិក ដើម្បីសាងសង់អគារសិក្សាចំនួន៥ខ្នង ស្មើនឹង៥៥បន្ទប់ និងទិញសម្ភារៈមួយចំនួនដូចជា ម៉ូតូ កង់ ឯកសណ្ឋានសិស្ស ឯកសណ្ឋានកីឡា សម្លៀកបំពាក់នៅផ្ទះ សម្ភារៈសិក្សា សម្ភារៈការិយាល័យ និងជួសជុលបន្ទប់សិក្សាជាដើមដើម្បីឧបត្ថម្ភដល់លោកគ្រូ អ្នកគ្រូ ចំនួន១៨៥នាក់ និងសិស្សានុសិស្សសរុបចំនួន ៥,៦៥០នាក់ ដែលកំពុងជួបការលំបាកនិងខ្វះខាតនៅគ្រឹះស្ថានសិក្សាសាធារណៈ ចំនួន១០ទីតាំងផ្សេងៗគ្នា។









នៅក្នុងនោះរួមមាន៖

- វិទ្យាល័យទ្រៀល ទទួលបានអគារសិក្សាថ្មីចំនួន ១ខ្នង កម្ពស់ ៣ជាន់ ស្មើនឹង ៣០បន្ទប់
- សាលាបឋមសិក្សាកកោះ ទទួលបានអគារសិក្សាថ្មីចំនួន ១ខ្នង កម្ពស់ ២ជាន់ ស្មើនឹង ១០បន្ទប់ និងតុ កៅអី កុំព្យូទ័រ ព្រមទាំងសម្ភារៈការិយាផ្សេងទៀត សរុបមានចំនួន ៥,៣៩៥ ដុល្លារអាម៉េរិក
- សាលាបឋមសិក្សាជាន់លែង ភូមិថ្មី ទទួលបានអគារសិក្សាថ្មីចំនួន ១ខ្នង មាន ១ជាន់ ស្មើនឹង ៥បន្ទប់ ព្រមទាំងកញ្ចប់ថវិកាចំនួន ១០,០០៥ ដុល្លារអាម៉េរិកសម្រាប់ជួសជុលអគារផ្សេងទៀត
- សាលាបឋមសិក្សាអូរសំបួរ ទទួលបានអគារសិក្សាថ្មីចំនួន ១ខ្នង មាន ១ជាន់ ស្មើនឹង ៥បន្ទប់ និងខ្លោងទ្វារថ្មី១ ក្នុងតម្លៃ ១៤,៥១៩ ដុល្លារអាម៉េរិក
- សាលាបឋមសិក្សា ហ៊ុនសែន ឈូកជីព្រះ ទទួលបានអគារសិក្សាថ្មីចំនួន ១ខ្នង មាន ១ជាន់ ស្មើនឹង ៥បន្ទប់
- សាលាបឋមសិក្សាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ តាំងគោក ទទួលបានក្តារខៀន តុ កៅអី កុំព្យូទ័រ ម៉ាស៊ីនព្រីនឯកសារ និងម៉ាស៊ីន LCD សរុបជាទឹកប្រាក់ ៦,៦០៥ ដុល្លារអាម៉េរិក
- សាលាបឋមសិក្សាស្វាយកាល់ទទួលបានឧបករណ៍បំពងសំឡេង និងផ្លូវបេតុងប្រវែង ៨៧ម៉ែត្រ សរុបជាថវិកា ១៤,១៣៣ ដុល្លារអាម៉េរិក
- សាលាបឋមសិក្សាត្រពាំងអារក្ស ទទួលបានកញ្ចប់ថវិកាជួសជុលបន្ទប់រៀនចំនួន ១,៦០០ ដុល្លារអាម៉េរិក
- សម្រាប់លោកគ្រូអ្នកគ្រូនៅក្នុងសាលាទាំង ១០ ចំនួន ១៥នាក់ដែលមានជីវភាពលំបាក និងមានកង្វះខាតមធ្យោបាយធ្វើដំណើរព្រមទាំងមានទីលំនៅឆ្ងាយពីសាលារៀនផងនោះ ទទួលបាន ម៉ូតូ ម្នាក់ ១គ្រឿង (សរុប ១៥គ្រឿង)
- ចំណែកលោកគ្រូ អ្នកគ្រូ ១៦នាក់ផ្សេងទៀតទទួលបានកង់ម្នាក់ ១គ្រឿង (សរុប ១៦គ្រឿង)
- សិស្សានុសិស្សដែលមានជីវភាពក្រីក្រ និងខ្វះខាតមធ្យោបាយធ្វើដំណើរនៅក្នុងសាលាទាំង ១០ សរុបចំនួន ៧៨៤នាក់ទទួលបានកង់ម្នាក់ ១គ្រឿង (សរុប ៧៨៤គ្រឿង)
- សិស្សានុសិស្សចំនួនទាំង ១០សាលាដែលមានចំនួនសរុប ៥៦៥០នាក់ ម្នាក់ៗទទួលបាន សម្ភារៈសិក្សា ឯកសណ្ឋានសិស្ស សម្លៀកបំពាក់ និងថវិកាម្នាក់ៗចំនួន ៤ម៉ឺនរៀល។








































# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធី បើកពិព័រណ៍រថយន្ត លើកទី២ ឆ្នាំ២០២៥












នាព្រឹកថ្ងៃសៅរ៍ ៣កើត ខែផល្គុណ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែមីនា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវរួមជាមួយលោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបទៀត បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបើកពិព័រណ៍រថយន្ត លើកទី២ ឆ្នាំ២០២៥ ដែលបានប្រារព្ធធ្វើឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនៅ ដឺ ព្រេមៀរ សេនធ័រ សែនសុខ ។

អ្នកឧកញ៉ា សេង ញ៉ក់ អគ្គនាយក ដឺ ព្រេមៀ សេនធ័រ សែនសុខ និងជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានលើកឡើងថា ពិធីតាំងបង្ហាញពិព័រណ៍រថយន្តនេះជាលើកទី២ ដោយមានក្រុមហ៊ុនចូលរួមច្រើនទ្វេដងជាងកាលលើកទី១។ អ្នកឧកញ៉ា បានបញ្ជាក់ថា ពិព័រណ៍នេះជាផ្នែកមួយបង្ហាញពីស្ថានភាពសេដ្ឋកិច្ចរីកចម្រើនក្រោមម្លប់នៃសុខសន្តិភាព និងការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា។

សូមបញ្ជាក់ថា ការរៀបចំតាំងបង្ហាញពិព័រណ៍រថយន្ត (Auto Show) លើកទី២ មានក្រុមហ៊ុនរថយន្ត ក៏ដូចជាដៃគូសហការផ្សេងទៀតចូលរួមជាង ៧០ក្រុមហ៊ុនដែលជាការប្រមូលផ្តុំក្រុមហ៊ុនផលិតរថយន្ត អ្នកលក់ និងអ្នកប្រើប្រាស់ដើម្បីស្វែងយល់ពីបច្ចេកវិទ្យាផលិតផលថ្មី ក៏ដូចជាទីផ្សារសកលនៅកម្ពុជាព្រមទាំងជាឱកាសទំនាក់ទំនងទៅកាន់អតិថិជន មួយវិញទៀតអ្នកប្រើប្រាស់ក៏នឹងមានឱកាសទទួលបាននូវបទពិសោធថ្មី ផលិតផលថ្មី បច្ចេកវិទ្យាថ្មី រួមជាមួយចំណេះដឹងផ្នែករថយន្តផងដែរ។

# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមជំនួបពិភាក្សាការងារ និងការផ្លូវផ្លូងធុរកិច្ច ជាមួយគណៈប្រតិភូធុរជននៃការិយាល័យ សភាពាណិជ្ជកម្មកម្ពុជាប្រចាំរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក

នាព្រឹកថ្ងៃចន្ទ ទី៣ ខែមីនា ឆ្នាំ២០២៥ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអញ្ជើញដឹកនាំជំនួបពិភាក្សាការងារ និងការផ្លូវផ្លូងធុរកិច្ចជាមួយគណៈប្រតិភូធុរជនដឹកនាំដោយ លោក គីម ឆាហួត អគ្គកុងស៊ុលកិត្តិយសកម្ពុជាប្រចាំនៅរដ្ឋកាលីហ្វ័រញ៉ា និងជាប្រធានការិយាល័យសភាពាណិជ្ជកម្មកម្ពុជាប្រចាំរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ ដែលជាថ្នាក់ដឹកនាំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចំនួន ១៣ក្រុមហ៊ុន ដឹកនាំដោយ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងសមាសភាពធុរជនជាតំណាងធុរកិច្ចពីសហរដ្ឋអាមេរិកប្រមាណ ២០ក្រុមហ៊ុនមកពីចម្រុះវិស័យ ដូចជា កសិកម្ម, អប់រំ, ដឹកជញ្ជូននិងព័ស្តុភារ, ថាមពល, បច្ចេកវិទ្យាព័ត៌មាន, ទេសចរណ៍និងបដិសណ្ឋារកិច្ច, សេវាកម្មច្បាប់និងពន្ធដារ, សុខាភិបាល, ធនាគារនិងហិរញ្ញវត្ថុ, ធនារ៉ាប់រង, អចលនទ្រព្យ, សំណង់, វិស្វកម្ម, អាហារនិងភេសជ្ជៈ ។ល។



ជាកិច្ចចាប់ផ្តើមឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជម្រាបទៅកាន់គណៈប្រតិភូធុរជនអំពីដំណើរអភិវឌ្ឍន៍ជាបន្តបន្ទាប់ឥតឈប់ឈររបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមកិច្ចដឹកនាំប្រកបដោយគតិបណ្ឌិតខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាលតាំងពីដើមរហូតមកដល់បច្ចុប្បន្ន ជាពិសេសជាមួយនឹងគោលនយោបាយក្នុងការបង្កើនពិពិធកម្មសេដ្ឋកិច្ចសំដៅសម្រេចឱ្យបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ជាប្រទេសដែលមានចំណូលខ្ពស់។ ទន្ទឹមនឹងនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានលើកឡើងអំពីសារតារនៃការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក៏ដូចជាបេសកកម្ម និងចក្ខុវិស័យក្នុងនាមជាសេនាធិការ និងជាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាលលើការងារគ្រប់គ្រងការវិនិយោគឯកជន និងតំបន់សេដ្ឋកិច្ចពិសេសដែលបាននិងកំពុងបន្តខិតខំជំរុញការកែលម្អធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច និងការវិនិយោគ ពិសេសការធ្វើឌីជីថលូបនីយកម្មក្នុងការផ្តល់សេវាសាធារណៈ ជាក់ស្តែងគឺការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (ប្រព័ន្ធ cdcIPM) ដែលសម្រួលដល់វិនិយោគិនក្នុងការដាក់ពាក្យស្នើសុំវិនិយោគបានពីគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈប្រព័ន្ធអ៊ីនធឺណេត។

ក្នុងឱកាសនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានជម្រាបជូនគណៈប្រតិភូធុរជនមកពីរដ្ឋកាលីហ្វ័រញ៉ានូវបេសកកម្ម និងតួនាទីស្នូលរបស់សមាគមឧកញ៉ាកម្ពុជា ដែលជាស្ថាប័នតំណាងឱ្យវិស័យឯកជននៅកម្ពុជាប្រមូលផ្តុំដោយសមាជិកសុទ្ធសឹងតែជាធុរជន និងពាណិជ្ជករដ៏មានសក្តានុពលហើយកំពុងតែវិនិយោគលើពហុវិស័យដើម្បីបង្កើតការងារជូនប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេស។

បន្ទាប់ពីបានស្តាប់ប្រសាសន៍លើកឡើងរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏ដូចជាការណែនាំខ្លួនរបស់សមាជិកសមាគមឧកញ៉ាកម្ពុជារួចមក គណៈប្រតិភូធុរជនពីរដ្ឋកាលីហ្វ័រញ៉ាបានសម្តែងការកោតសរសើរ និងបង្ហាញចំណាប់អារម្មណ៍ខ្ពស់លើការរីកចម្រើនគួរឱ្យកត់សម្គាល់របស់កម្ពុជា។ ទន្ទឹមនឹងនេះ គណៈប្រតិភូធុរជនក៏បានធ្វើការវាយតម្លៃខ្ពស់ចំពោះការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក៏ដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផ្ទាល់ក្នុងការសម្របសម្រួល និងថៃទាំគាំទ្រដល់វិស័យឯកជនព្រមទាំងបានបង្ហាញនូវឆន្ទៈក្នុងការពិនិត្យលទ្ធភាពដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងរដ្ឋកាលីហ្វ័រញ៉ា និងកម្ពុជា ជាពិសេសលើទំនាក់ទំនងសេដ្ឋកិច្ច និងការវិនិយោគរវាងភាគីទាំងពីរ។












# អ្នកឧកញ៉ា ហ៊ិន ឡាក់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម ក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ ស្ដីពី "យុទ្ធសាស្ត្រកំណើនថ្មីរបស់កម្ពុជា ៖ អាទិភាពសម្រាប់ការអភិវឌ្ឍប្រកបដោយគុណភាព និងនិរន្តរភាព"




នាព្រឹកថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ិន ឡាក់ អគ្គលេខាធិការ និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមទាំងសមាជិកសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបទៀត បានចូលរួមក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៥ ស្ដីពី «យុទ្ធសាស្ត្រកំណើនថ្មីរបស់កម្ពុជា៖ អាទិភាពសម្រាប់ការអភិវឌ្ឍប្រកបដោយគុណភាព និងនិរន្តរភាព» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ពិធីនេះប្រារព្ធធ្វើឡើងនៅសណ្ឋាគារ សុខា ភ្នំពេញ ដែលរៀបចំដោយវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ( CDRI)។

សម្រាប់សន្និសីទឆ្នាំនេះ បានធ្វើការសម្របសម្រួលកិច្ចសន្ទនាក្នុងចំណោមអ្នកជំនាញជាន់ខ្ពស់ជាតិ និងអន្តរជាតិផងដែរដើម្បីយល់ឱ្យកាន់តែច្បាស់អំពីបញ្ហាប្រឈមចំពោះមុខ និងកាលានុវត្តភាពដើម្បីជួយកម្ពុជា ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយប្រសិទ្ធភាពក្នុងបរិការណ៍នៃស្ថានភាពដែលមានភាពមិនច្បាស់លាស់ដែលអាចប៉ះពាល់ដល់គន្លង នៃការអភិវឌ្ឍនាពេលអនាគតនៅកម្ពុជា។

ក្នុងឱកាសនេះដែរ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** បានបំផុសគំនិតឱ្យយកចិត្តទុកដាក់ពិភាក្សាលើបរិការណ៍សកលរួមមាន៖

១. ការកើនឡើងនូវចរន្តគាំពារនិយមដែលអាចឈានទៅដល់សង្គ្រាមពាណិជ្ជកម្ម និងសង្គ្រាមបច្ចេកវិទ្យា

២. ការចាប់ផ្ដើមពឹងផ្អែកកាន់តែខ្លាំងឡើងលើសេដ្ឋកិច្ចក្នុងតំបន់ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច

៣. សម្ទុះនៃការធ្វើបរិវត្តកម្មឌីជីថលកាន់តែលឿន ជាពិសេសលើបញ្ញាសិប្បនិម្មិត និង

៤. និន្នាការកើនឡើងនៃអន្តរកាលបៃតង តួយ៉ាងដូចជាការវិនិយោគលើថាមពលកកើតឡើង និងរថយន្តអគ្គិសនីជាដើម ។

**សម្ដេច** បានបន្ថែមថា ក្នុងបរិការណ៍កម្ពុជា សូមមានការពិភាក្សាឱ្យបានផុលផុសលើ៖ ការកំណត់ និងអភិវឌ្ឍន៍វិស័យដែលជាប្រភពកំណើនថ្មី, ការត្រៀមលក្ខណៈចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច, យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និង មធ្យម និងធុរកិច្ចបង្កើតថ្មី និងការអភិវឌ្ឍជំនាញបច្ចេកទេសបំពេញគម្លាតនៃជំនាញ (Skill gap) និងការបំពេញតម្រូវការនាពេលអនាគត ។

សូមបញ្ជាក់ថា សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា គឺជាសន្និសីទដ៏សំខាន់បំផុតមួយនៅកម្ពុជាដែលវិទ្យាស្ថាន CDRI បានរៀបចំអស់រយៈពេល១៦ឆ្នាំមកហើយដោយមានការចូលរួមពីថ្នាក់ដឹកនាំប្រមាណ ៤០០នាក់ មកពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៃរាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា ស្ថានទូតបរទេស តំណាងបេសកកម្មការទូតបរទេសនានាប្រចាំព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារអង្គការសហប្រជាជាតិ


's New Growth Strategy
Phnom Penh, 4 March 2025


ambodia Outlook Conference 2025
r High Quality and Sustainable Development


CAMBODIA OUTLOOK CONFERENCE















# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ រួមទាំងសមាជិកសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបទៀតបានចូលរួមក្នុង "ពិធីទទួលស្វាគមន៍ និងជំនួបផ្គូផ្គងធុរកិច្ច" រៀបចំដោយ អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO)




នាថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជារួមជាមួយសមាជិកសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបទៀតបានចូលរួមក្នុង "ពិធីទទួលស្វាគមន៍ និងជំនួបផ្គូផ្គងធុរកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម វង្សីវិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដែលពិធីនេះប្រារព្ធធ្វើឡើងនៅសណ្ឋាគាររ៉ាហ្វិល ឡឺរ៉ូយ៉ាល់ និងរៀបចំដោយអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ដោយមានការគាំទ្រពីសមាគមពាណិជ្ជកម្មនិងវិនិយោគកម្ពុជា-ជប៉ុន (CJBI) និងសមាគមធុរកិច្ចជប៉ុននៅកម្ពុជា (JBAC) ។

ក្នុងឱកាសនៃជំនួបខាងលើនេះ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចំនួន ១០ក្រុមហ៊ុន និងតំណាងក្រុមហ៊ុនកម្ពុជាដទៃទៀតចំនួន ៣០ក្រុមហ៊ុន បានជួបផ្គូផ្គងធុរកិច្ចជាមួយគណៈប្រតិភូធុរកិច្ចជប៉ុនចំនួន៤៤ក្រុមហ៊ុនមកពីចម្រុះវិស័យដើម្បីស្វែងរកឱកាសចាប់ដៃគូវិនិយោគ និងកិច្ចសហការធុរកិច្ចទៅវិញទៅមកនៅក្នុងវិស័យអាទិភាពរៀងៗខ្លួន។

លោក Kohei Wakabayashi ប្រធានតំណាងអង្គការ JETRO បានឱ្យដឹងថា ក្រុមវិនិយោគិនទាំងនេះមិនត្រឹមតែមកពីប្រទេសជប៉ុនប៉ុណ្ណោះទេថែមទាំងមកពីប្រទេសថៃ វៀតណាម ចិន និងប្រទេសផ្សេងៗទៀតផងដែរហើយក្រុមហ៊ុនទាំងនេះមានបំណងពង្រីកអាជីវកម្ម ក្រៅប្រទេសរបស់ខ្លួន ខណៈកាលពីឆ្នាំ២០២៤ ក្រុមហ៊ុនជប៉ុនជាង ៩០បានចុះបញ្ជីវិនិយោគនៅកម្ពុជា។ លោកបានជម្រាបជូនបន្ថែមទៀតថាក្រុមហ៊ុន ជប៉ុនទាំងនេះកំពុងពិចារណាយ៉ាងយកចិត្តទុកដាក់លើការវិនិយោគ និងធ្វើអាជីវកម្មនៅកម្ពុជា ហេតុដូច្នេះហើយទើប JETRO រៀបចំជំនួបរវាងពួកគេនិងមន្ត្រីជាន់ខ្ពស់ក៏ដូចជាធុរជននៅកម្ពុជា ដើម្បីសិក្សានិងផ្គូផ្គងធុរកិច្ចទៅវិញទៅមក។


















ថ្លែងក្នុងពិធីខាងលើ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ វង្សី វិស្សុត បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានកំពុងបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការតាមដាន និងដោះស្រាយបញ្ហាប្រឈមនិងកង្វល់នានារបស់វិស័យឯកជន និងជាពិសេសលើកទឹកចិត្តឱ្យសហគមន៍វិនិយោគិនជប៉ុនលើកឡើងអំពីបញ្ហាប្រឈមនានាឱ្យចំៗដោយបើកចំហ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តពិភាក្សាអំពីគោលនយោបាយថ្មីរបស់ JETRO ដែលមានបំណងលើកស្ទួយធុរកិច្ចថ្មីកម្ពុជាដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការធុរកិច្ចថ្មីកម្ពុជា-ជប៉ុន និងបន្តជំរុញយន្តការនៃការបង្កើតក្រុមការងារពិសេសដែលមានតំណាងពីក្រសួង-ស្ថាប័នដើម្បីសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយ JETRO និងក្រុមហ៊ុនជប៉ុន។

ទន្ទឹមគ្នានេះរាជរដ្ឋាភិបាលនឹងបន្តជំរុញកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ជប៉ុនដើម្បីចាប់យកសក្តានុពលជាច្រើន នៃទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគរបស់ប្រទេសទាំងពីរបន្ថែមទៀត ,បន្តការសិក្សាសមិទ្ធិលទ្ធភាព (Feasibility Study) ក្នុងការបង្កើតតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា-ជប៉ុន, បន្តពង្រឹង និងបង្កើនសមត្ថភាពផលិតកម្ម គុណភាព និងស្តង់ដារទំនិញកម្ពុជាដើម្បីនាំចូលទីផ្សារជប៉ុន និងបន្តគាំទ្រ និងជំរុញក្រុមហ៊ុនជប៉ុនក្នុងការវិនិយោគក្នុងវិស័យទូរគមនាគមន៍ និងបរិវត្តកម្មឌីជីថល ពិសេសលើការអភិវឌ្ឍប្រព័ន្ធសេវាអ៊ីធឺណិត, វិស័យពាណិជ្ជកម្ម ហេដ្ឋារចនាសម្ព័ន្ធឌីជីថល, សហគ្រាសធុនតូចនិងមធ្យម, កសិ-ឧស្សាហកម្ម, ឧស្សាហកម្មបៃតង ព្រមទាំងបន្តលើកទឹកចិត្ត និងពង្រឹងយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) ។ល។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានលើកឡើងផងដែរថាក្នុងរយៈពេល១៥ឆ្នាំកន្លងមកអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) ប្រចាំនៅរាជធានីភ្នំពេញបានបំពេញបេសកកម្មរបស់ខ្លួនក្នុងការជួយសម្របសម្រួលពាណិជ្ជកម្មរវាង កម្ពុជា-ជប៉ុន តាមរយៈការរៀប ចំព្រឹត្តិការណ៍សំខាន់ៗដូចជាពិព័រណ៍ពាណិជ្ជកម្ម ការបណ្តុះបណ្តាល ទំនាក់ទំនងធុរកិច្ច និងការផ្គូផ្គងក្រុមហ៊ុនរវាងប្រទេសទាំងពីរជាដើម។ ជាលទ្ធផល ប្រទេសជប៉ុនបាននិងកំពុងក្លាយជាដៃគូពាណិជ្ជកម្មដ៏សំខាន់សម្រាប់កម្ពុជាដែលឆ្លុះបញ្ចាំងតាមរយៈការបន្តកើនឡើងនៃទំហំពាណិជ្ជកម្មទ្វេភាគីសរុបពី ១,៤ពាន់លានដុល្លារអាម៉េរិកនៅឆ្នាំ២០១៧ ដល់ ២.២ពាន់លានដុល្លារអាម៉េរិកនៅឆ្នាំ២០២៤។

សូមជម្រាបថា ក្នុងឆ្នាំ២០២៤ កម្ពុជាបានចុះបញ្ជីក្រុមហ៊ុនជប៉ុនប្រមាណ ៩០ក្រុមហ៊ុនដោយមានការកើនឡើង ២០.៥៥% បើប្រៀបធៀបនឹងឆ្នាំ២០២៣។ ជាមួយគ្នានេះ ក្រុមហ៊ុនជប៉ុនបានវិនិយោគលើវិស័យឧស្សាហកម្ម កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធដែលបានចូលរួមជាវិជ្ជមានដល់ដំណើរអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជាតាមរយៈការបង្កើតការងាររាប់ពាន់កន្លែង ការបណ្តុះបណ្តាលជំនាញ និងផ្ទេរបច្ចេកវិទ្យាដែលជាការរួមចំណែកពង្រឹងភាពប្រកួតប្រជែងឧស្សាហកម្ម និងផលិតភាពការងាររបស់កម្ពុជា។ ជាក់ស្តែងក្រុមហ៊ុនជប៉ុនល្បីៗដូចជា Minebea, AEON និង Toyota បាននិងកំពុងដំណើរការយ៉ាងល្អប្រសើរ និងបានបន្តបង្កើនទីតាំងរោងចក្រ និងទីតាំងធុរកិច្ចរបស់ខ្លួននៅកម្ពុជាជាបន្តបន្ទាប់។

# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុង "ជំនួបផ្គូផ្គងធុរកិច្ច និងអាហារពេលល្ងាច" ក្រោមអធិបតីភាព ឯកឧត្តម ស៊ុន ចាន់ថុល និងឯកឧត្តម Wang Wenbin ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំកម្ពុជា













នាល្ងាចថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយសមាជិកសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបទៀតបានចូលរួមក្នុង "ជំនួបផ្គូផ្គងធុរកិច្ច និងអាហារពេលល្ងាច» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា( ក.អ.ក. ) និង ឯកឧត្តម Wang Wenbin ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជាដែលពិធីនេះប្រារព្ធធ្វើឡើងនៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងមន្ត្រីពាក់ព័ន្ធជាច្រើនរូបផ្សេងទៀត។

ក្នុងឱកាសនៃជំនួបខាងលើនេះ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចំនួន ១៥ក្រុមហ៊ុនក៏បានជួបផ្គូផ្គងធុរកិច្ចជាមួយគណៈប្រតិធុរកិច្ចចិនចំនួន៥០ក្រុមហ៊ុនមកពីចម្រុះវិស័យ ដឹកនាំដោយលោកស្រី Li Fengzhi អភិបាលរងនៃគណៈអភិបាលរដ្ឋបាលប្រជាជន ក្រុងចឹងចូវ ខេត្តហឺណាន សាធារណរដ្ឋប្រជាមានិតចិន។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះវត្តមានរបស់ឯកឧត្តមឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា ក៏ដូចជាលោកស្រីអភិបាលរង នៃគណៈអភិបាលរដ្ឋបាលប្រជាជនក្រុងចឹងចូវ ព្រមទាំងគណៈប្រតិភូអមដំណើរទាំងអស់ដែលបានអញ្ជើញចូលរួមយ៉ាងកុះករនាឱកាសនេះ និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដែលបានចំណាយពេលវេលាមកបំពេញទស្សកិច្ចស្វែងយល់ដោយផ្ទាល់អំពីបរិយាកាសវិនិយោគនៅកម្ពុជានាពេលបច្ចុប្បន្នដែលបង្ហាញឱ្យឃើញពីចំណងមិត្តភាព កម្ពុជា-ចិន ដ៏រឹងមាំស្អិតរមួតក្នុងនាមជាមិត្តដែកថែប។ ជាមួយគ្នានេះ ឯកឧត្តមឯកអគ្គរដ្ឋទូត បានវាយតម្លៃខ្ពស់ចំពោះការអភិវឌ្ឍយ៉ាងធំធេងនៃទំនាក់ទំនងកម្ពុជា-ចិន ដែលត្រូវបានពូនជ្រំដោយយកចិត្តទុកដាក់ពីសំណាក់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ និងកំពុងបន្តរីកចម្រើនកាន់តែរឹងមាំឥតឈប់ឈរថែមទៀត និងបានរំលេចដែរថា កម្ពុជាគឺពិតជាគោលដៅវិនិយោគមួយដ៏ប្រពៃបើធៀបនឹងគោលដៅដទៃនៅក្នុងតំបន់។

លោកស្រីអភិបាលរង បានគោរពថ្លែងអំណរគុណចំពោះបដិសណ្ឋារកិច្ចដ៏កក់ក្ដៅប្រកបដោយមិត្តភាពនិងការរៀបចំជំនួបពិភាក្សាដ៏មានសារៈប្រយោជន៍សម្រាប់គណៈប្រតិភូទាំងអស់ពិសេសគណៈប្រតិភូវិនិយោគិនទាំង៥០ក្រុមហ៊ុនដែលចូលរួមក្នុងដំណើរទស្សនកិច្ចនេះ។ លោកស្រីក៏បានជម្រាបអំពីគោលបំណងនៃការបំពេញទស្សនកិច្ចរបស់គណៈប្រតិភូចិនក្នុងការស្វែងយល់អំពីបរិយាកាសវិនិយោគនៅកម្ពុជា និងស្វែងរកដៃគូវិនិយោគក្នុងវិស័យអាទិភាពរបស់ខ្លួនផងដែរ។ បន្ថែមលើនេះ លោកស្រីបានរំលេចជាពិសេសអំពីគម្រោងស្នើសុំវិនិយោគសួនកសិ-ឧស្សាហកម្មសម្រាប់កិច្ចសហប្រតិបត្តិការស៊ីជម្រៅលើការកែច្នៃផលិតផលកសិកម្មនៅកម្ពុជារបស់រដ្ឋបាលខេត្តហ៊ឺណាន ដែលត្រូវបានរំពឹងថានឹងវិនិយោគឱ្យក្លាយជាតំបន់ពាណិជ្ជកម្មពិសេសលើផលិតផលកសិកម្ម, ការច្នៃផលិតផលកសិកម្ម, ការផ្ដល់សេវាកម្មលើបច្ចេកវិទ្យាកសិកម្ម និងជាទីតាំងស្តុកផលិតផលកសិកម្មតាមរយៈការទាក់ទាញបណ្ដាក្រុមហ៊ុនផ្សេងៗដែលមានមុខសញ្ញាអាជីវកម្មពាក់ព័ន្ធនឹងវិស័យកសិកម្មបែបទំនើប។

ជំនួបផ្គូផ្គងធុរកិច្ច និងអាហារពេលល្ងាចនេះបានប្រព្រឹត្តទៅដោយភាពរលូនដោយគណៈប្រតិភូកម្ពុជា និងចិន បានជួបផ្លាស់ប្ដូរទំនាក់ទំនងធុរកិច្ចជាមួយគ្នាក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។











# សមាគមឧកញ៉ាកម្ពុជា ប្រារព្ធសន្និបាតលើកទី២ ដើម្បីបូកសរុបលទ្ធផលការងារក្នុងឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ ព្រមទាំងពិធីពិសាភោជនាហារសាមគ្គី នៃគ្រួសារសមាគមឧកញ៉ាកម្ពុជា



នាព្រឹកថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញថ្លែងមតិស្វាគមន៍ក្នុងពិធីបើកសន្និបាតលើកទី២ដើម្បីបូកសរុបលទ្ធផលការងារក្នុងឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ នៅ ដីព្រមៀ សែនធំ សែនសុខ ដោយមានការអញ្ជើញចូលរួមពីសំណាក់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាអនុប្រធាន សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជាប្រមាណជា ៣០០រូប។

លោកអ្នកឧកញ៉ាប្រធានបានបញ្ជាក់ថា សន្និបាតប្រចាំឆ្នាំគឺជាវឌ្ឍនភាពថ្មីមួយទៀតរបស់សមាគមឧកញ៉ាកម្ពុជា និងជាវេទិកាដ៏មានសារៈសំខាន់ដើម្បីឱ្យលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជាបានផ្លាស់ប្តូរមតិយោបល់ក៏ដូចជាអនុសាសន៍នានាសំដៅរួមគ្នាបូកសរុបនិងវាយតម្លៃសមិទ្ធផលការងារក្នុងឆ្នាំកន្លងមកដើម្បីលើកកម្ពស់សមត្ថភាពការ ទទួលខុសត្រូវ និងបន្តនិរន្តរភាពរបស់សមាគម។

លោកអ្នកឧកញ៉ាបានបន្ថែមថា តាមរយៈបទបង្ហាញនានារបស់អគ្គលេខាធិការក៏ដូចជាតំណាងគណៈកម្មការជំនាញ សមាជិកទាំងអស់ក៏អាចចូលរួមក្នុងការលើកជាសំណួរ ឬអនុសាសន៍ល្អៗដើម្បីពិភាក្សា និងស្វែងយល់អំពីតួនាទី ភារកិច្ច គោលបំណង និងដំណើរការរបស់សមាគមសំដៅការពារផលប្រយោជន៍របស់ខ្លួនផងរបស់សមាគមផង និងដើម្បីពង្រឹងកិច្ចសហការជាមួយស្ថាប័នរដ្ឋជាពិសេសជាមួយរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព។



ក្នុងឱកាសនេះ ក៏មានការរៀបចំវគ្គសំនួរ-ចម្លើយពីសមាជិកនៃអង្គសន្និបាតដោយមានការបកស្រាយពីលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដោយ លោកអ្នកឧកញ៉ា លី ហួរ ប្រធានគណៈកម្មការសមាជិកភាព វិន័យ និងក្រមសីលធម៌, អ្នកឧកញ៉ា លាង ម៉េង ប្រធានគណៈកម្មការច្បាប់, អ្នកឧកញ៉ា ផៃ ហុកឈួន ប្រធានគណៈកម្មការរដ្ឋបាល និងហិរញ្ញវត្ថុ, អ្នកឧកញ៉ា សៀ ឬទ្ធី ប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ និងអន្តរជាតិ, អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការសមាគម, អ្នកឧកញ៉ា ទី គឹមស្រ៊ាន និង ឧកញ៉ា កង លាប ដែលជាសមាជិកក្រុមអ្នកច្បាប់ នៃសមាគមឧកញ៉ាកម្ពុជាអំពីបេសកកម្ម សកម្មភាពការងារ ក៏ដូចជាអត្ថប្រយោជន៍នានា ព្រមទាំងការចូលរួមផ្តល់នូវមតិយោបល់ល្អៗប្រកបដោយគុណតម្លៃដើម្បីជាទស្សនាទានក្នុងការពង្រឹងសកម្មភាពការងារ និងការអភិវឌ្ឍសមាគមឆ្ពោះទៅកាន់ភាពរីកចម្រើនថែមទៀត។

សូមបញ្ជាក់ថា តាមរយៈវេទិកានេះបានផ្តល់ឱកាសដល់សមាជិកគ្រប់ៗរូបអាចចូលរួមបញ្ចេញមតិ ផ្តល់យោបល់ និងទទួលបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយអំពីសមិទ្ធផលការងារប្រចាំឆ្នាំនីមួយៗរបស់សមាគមដែលបាននឹងកំពុងបំពេញបេសកកម្មក្នុងគោលដៅថែរក្សា និងលើកកម្ពស់ឧត្តមភាពដ៏ឧត្តុង្គឧត្តមនៃគោរមងារឧកញ៉ាដើម្បីចូលរួមអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព តាមរយៈសកម្មភាពសប្បុរិសធម៌ ការជំរុញពាណិជ្ជកម្ម និងទាក់ទាញវិនិយោគដើម្បីបង្កើតការងារជូនប្រជាពលរដ្ឋខ្មែររាប់ម៉ឺនកន្លែងនៅទូទាំងប្រទេស។




































## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតប្រចាំឆ្នាំលើកទី២ បូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅផែនការ ឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា

នារសៀលថ្ងៃសុក្រ ទី១៤ ខែមីនា ឆ្នាំ២០២៥ **សម្តេចមហាបវរធិបតី** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតប្រចាំឆ្នាំលើកទី២ បូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅផែនការ ឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា និងថ្លែងនូវសុន្ទរកថាគន្លឹះ ព្រមទាំងផ្តល់អនុសាសន៍ប្រកបដោយគតិបណ្ឌិតដល់អង្គសន្និបាតផងដែរ។

**សម្តេចធិបតី** បានមានប្រសាសន៍គូសបញ្ជាក់ថា សមាគមឧកញ៉ាកម្ពុជា បានរួមចំណែកយ៉ាងសំខាន់ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងជំរុញ និងពង្រឹងការចូលរួមអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិឱ្យកាន់តែសកម្មខ្លាំងក្លា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ក៏ដូចជាការលើកកម្ពស់ ពង្រឹងមុខងារ និងតួនាទីរបស់សមាគមថែមមួយកម្រិតទៀត បន្ថែមពីនោះ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា និងគោរមវន្ត ទាំងអស់ជានិច្ចកាលតែងតែចូលរួមក្នុងសកម្មភាពសង្គម មនុស្សធម៌ និងសប្បុរិសធម៌នាពេលកន្លងមក។ **សម្តេចធិបតី** បានបន្ថែមថា រាជរដ្ឋាភិបាលក៏កត់សម្គាល់ឃើញថារាល់ការអំពាវនាវរបស់រាជរដ្ឋាភិបាលតែងតែទទួលបានការគាំទ្រចូលរួមយ៉ាងសកម្មពីសំណាក់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ាផងដែរ។

ក្នុងឱកាសនេះដែរ **សម្តេចធិបតី** ក៏បានថ្លែងថា គោរមងារឧកញ៉ាបានផ្តល់ជូនអ្នកមានគុណសម្បត្តិ និងដែលបានរួមចំណែកក្នុងការជួយសង្គមជាតិ និងប្រជាជន ព្រមទាំងបានខិតខំ និងទទួលផលពីការតស៊ូរបស់ខ្លួនក្រោមសុខសន្តិភាពរបស់ប្រទេស ហើយការរីកចម្រើននេះមិនត្រឹមតែសម្រាប់ផ្ទាល់ខ្លួនទេ ប៉ុន្តែសម្រាប់ជួយដល់អ្នកពាក់ព័ន្ធ បុគ្គលិក និងការរួមចំណែកក្នុងការកសាងសមិទ្ធផលសង្គម កិច្ចការមនុស្សធម៌ និងជួយអ្នកដទៃ។ ដូច្នេះ សូមគោរមវន្តទាំងអស់ថែរក្សាកិត្តិនាម កិត្តិយស និងគុណសម្បត្តិដ៏ល្អផូរផង់នេះសម្រាប់បន្តជួយដល់សង្គមជាតិ និងគោរមងារដ៏មានតម្លៃឱ្យបានយូរអង្វែង។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានបន្ថែមថា រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកកិច្ចការទូតសេដ្ឋកិច្ចជាកិច្ចការអាទិភាពនិងយកចិត្តទុកដាក់ដោយមិនត្រឹមតែការធ្វើការទាក់ទាញក្នុងប្រទេសប៉ុណ្ណោះទេតែក៏បានជំរុញការទាក់ទាញការវិនិយោគពីក្រៅប្រទេសផងដែរ។ ជាមួយគ្នានេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដល់សភាពាណិជ្ជកម្មកម្ពុជា និងសមាគមឧកញ៉ាកម្ពុជាដែលបានផ្តល់ការសហការ គាំទ្រ និងធ្វើសកម្មភាពយ៉ាងសកម្មក្នុងការភ្ជាប់វិស័យឯកជនជាមួយនឹងវិស័យឯកជនដែលបង្កើនភាពទាក់ទាញ និងជំរុញការវិនិយោគឱ្យមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ខណៈដែលរាជរដ្ឋាភិបាលមិនអាចធ្វើតែម្នាក់ឯងបាននោះទេពោលគឺដើរតួជាស្ពានភ្ជាប់ដាក់ចេញនូវគោលនយោបាយ និងបើកច្រកព្រំដែនរវាងវិស័យឯកជន គឺជាអ្នកឆ្លើយឆ្លងជាមួយនឹងវិស័យឯកជន និងបន្តទំនាក់ទំនងប្រទាក់ក្រឡាជាមួយគ្នាទៅវិញទៅមក។



**សម្តេច** បានបន្ថែមថា ក្នុងន័យនេះយើងទាំងអស់គ្នាត្រូវប្រើប្រាស់កម្លាំងសរុបទើបអាចទាក់ទាញវិនិយោគិនបានព្រោះវិស័យឯកជនគឺជឿជាក់លើវិស័យឯកជនដូចគ្នា។ ជាលទ្ធផលគួរជាទីមោទននៅក្នុងឆ្នាំ២០២៤កម្ពុជាទទួលបានការស្នើសុំ និងអនុម័តគម្រោងជាផ្លូវការបានចំនួន ៤១៤គម្រោង ស្មើនឹងទឹកប្រាក់ជាង ៦,៨ប៊ីលានដុល្លារ ពោលគឺជាឆ្នាំដែលមានការវិនិយោគច្រើនជាងគេមិនធ្លាប់មាននៅកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានប្រកាសថា រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តល់ការលើកទឹកចិត្ត និងបង្កលក្ខណៈងាយស្រួល សម្រាប់វិស័យឯកជន ដែលវិនិយោគលើការវិនិយោគផលិតផលគាំទ្រខ្សែច្រវាក់ផលិតកម្មដើម្បីធានាដល់និរន្តរភាព និងកម្លាំងនៃការផលិតក្នុងស្រុកឱ្យកាន់តែសកម្ម មានតម្លៃទាប និងប្រសិទ្ធភាពខ្ពស់សម្រាប់បំពេញសេចក្តីត្រូវការក្នុងស្រុកផង និងនាំចេញផង។

មុននឹងបញ្ចប់ **សម្តេច** បានគូសបញ្ជាក់ថា សន្តិភាពនៅតែជាកត្តាគន្លឹះសម្រាប់កម្ពុជាសម្រាប់ទាំងអស់គ្នា និងសម្រាប់ការវិនិយោគពិសេសសម្រាប់វិស័យឯកជនតែម្តង។ **សម្តេច** បានសង្កត់ធ្ងន់ថា សន្តិភាពគឺជាកត្តាគន្លឹះ និងអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានប្រកាន់គោលជំហ និងប្តេជ្ញាថែរក្សាឱ្យខាងតែបានទោះក្នុងតម្លៃណាក៏ដោយ ពិសេសតាមរយៈការការពារអធិបតេយ្យភាព ស្ថិរភាព និងបូរណភាពទឹកដី។ ពេលណាមានសង្គ្រាមអ្នកដែលលំបាកមុនគេនោះគឺកងទ័ព និងប្រជាជននៅទីតាំងដែលមានជម្លោះ បន្ទាប់ទៀតគឺប្រជាជននិងសេដ្ឋកិច្ចកម្ពុជា រួមទាំងវិនិយោគិនផងដែរ។ ដូច្នេះ រាជរដ្ឋាភិបាលតែងមានវិធីសាស្ត្រក្នុងការដោះស្រាយ និងធ្វើការយ៉ាងប្រាកដប្រជា ប្រកាន់ខ្ជាប់នូវការដោះស្រាយដោយសន្តិវិធី ចរចាលើកិច្ចការបច្ចេកទេស និងក្របខណ្ឌច្បាប់ និងកិច្ចសហប្រតិបត្តិការច្បាស់លាស់ ប៉ុន្តែក៏នៅតែរក្សាសិទ្ធិក្នុងការការពារខ្លួន ការពារអធិបតេយ្យ និងបូរណភាពទឹកដីដោយបានត្រៀមលក្ខណៈគ្រប់យន្តការទាំងអស់។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ **សម្តេចធិបតី** បានផ្តល់នូវផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់បំពាក់មេដាយជាតូបការដល់ អ្នកឧកញ៉ា ឧកញ៉ាជា សមាជិក នៃសមាគមឧកញ៉ាកម្ពុជាព្រមទាំងលោក លោកស្រី ជាសប្បុរសជននានាផងដែរ។

































## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធីពិសាភោជនាហារសាមគ្គីគ្រួសារសមាគមឧកញ៉ាកម្ពុជា

នាល្ងាចថ្ងៃសុក្រ ទី១៤ ខែមីនា ឆ្នាំ២០២៥ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសសមាគមឧកញ៉ាកម្ពុជាបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធី «ពិសាភោជនាហារសាមគ្គី នៃគ្រួសារសមាគមឧកញ៉ាកម្ពុជា» ដើម្បីអបអរសាទរក្នុងឱកាស នៃពិធីបិទសន្និបាតប្រចាំឆ្នាំ លើកទី២ ដើម្បីបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅផែនការឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា។

ក្នុងពិធីនេះក៏មានការអញ្ជើញចូលរួមពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសមាជិក សមាជិកាឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ឥស្សរជនជាន់ខ្ពស់ នៃរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាថ្នាក់ដឹកនាំនិងតំណាងវិស័យឯកជនជាច្រើនរូបទៀតផងដែរ។

ជាកិច្ចចាប់ផ្តើម **សម្តេចតេជោ** បានមានប្រសាសន៍ថ្លែងអំណរគុណចំពោះសកម្មភាពរបស់សមាគមឧកញ៉ាកម្ពុជា ដែលបានធ្វើនាពេលកន្លងសម្រាប់សង្គមជាតិ ជាពិសេសរួមគ្នាថ្វាយដង្វាយដល់ **ព្រះមហាក្សត្រ** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ដើម្បីដង្ហែក្នុងព្រះរាជសកម្មភាពមនុស្សធម៌របស់ព្រះអង្គទាំងទ្វេ។

ជាមួយគ្នានេះ **សម្តេច** សង្ឃឹមថាទាំងរាជរដ្ឋាភិបាល បក្សនយោបាយនានា និងប្រជាជនកម្ពុជានឹងរួមគ្នាធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមានចំណូលខ្ពស់ដោយ **សម្តេចតេជោ** បានអំពាវនាវដល់អ្នកធុរកិច្ចនៅកម្ពុជាទាំងអស់មិនថាឧកញ៉ា ឬមិនឧកញ៉ានោះទេ គប្បីត្រូវរួមគ្នាធ្វើឱ្យសម្រេចបាននូវគោលដៅនេះ។ ទន្ទឹមនឹងនេះ **សម្តេចតេជោ** សូមឱ្យសមាគមឧកញ៉ាដែលមានអ្នកវិនិយោគច្រើននៅទីនេះជួយទៅ ដល់វិស័យកសិកម្ម និងការគាំទ្រនូវតម្លៃកសិផល ជាពិសេសគឺតម្លៃស្រូវតែម្តង។

**សម្តេច** បានលើកឡើងថា នៅពេលដែលមានវិបត្តិស្រូវដែលប្រជាជនត្រូវការលក់ចេញ មានឧកញ៉ាខ្លះ ដែលត្រូវការជួយឧបត្ថម្ភ ជាជនជាអង្ករ ដូច្នេះឧកញ៉ាទាំងអស់នោះអាចទៅជួយទិញស្រូវ ដើម្បីមកកិនទៅជាអង្ករហើយយកទៅចែកចាយជូនប្រជាជន ឬបុគ្គលិករបស់ខ្លួនបាន។ **សម្តេច** ក៏បានបន្ថែមថា គួរតែពិនិត្យអំពីការខិតខំដើម្បីបង្កើនតម្លៃបន្ថែមតាមរយៈផលិតកម្មកសិកម្មដែលកម្ពុជាមានច្រើនណាស់ដូចជាស្វាយចន្ទីជាដើម ខណៈដែលកម្ពុជាកំពុងតែប្រែក្លាយទៅជាប្រទេសដែលដាំស្វាយចន្ទីស្រស់ច្រើនជាងគេនៅលើពិភពលោក។

**សម្តេចតេជោ** បានគូសបញ្ជាក់ថា បើសិនជាកម្ពុជាដាំដំណាំឧស្សាហកម្មបានច្រើនដូចជាស្វាយចន្ទីជាដើមនោះនឹងអាចរួមចំណែកលើកកម្ពស់ជីវភាពរបស់ប្រជាកសិករផង និងអាចបង្កើតបាននូវគម្របព្រៃឈើកាន់តែធំដែលធានាឱ្យភាពបៃតងរបស់កម្ពុជាដែលចំណុចនេះគួរតែត្រូវបានរួមគ្នាឱ្យកម្ពុជាក្លាយទៅជាប្រទេសដែលមានទាំងកសិ-ឧស្សាហកម្ម និងកសិ-ពាណិជ្ជកម្ម។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសសមាគមឧកញ៉ាកម្ពុជា ក៏បានអនុញ្ញាតដល់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ប្រធាន អនុប្រធាន សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានថតរូបអនុស្សាវរីយ៍ជាមួយ **សម្តេច** ផងដែរ។






























អបអរសាទរ
សន្និបាតប្រចាំឆ្នាំ ២០២៤
និងពិធីពិសាភោជនាហារសាមគ្គី នៃគ្រួសារសមាគមឧកញ៉ាកម្ពុជា













# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ នៃសមាគមឧកញ៉ាកម្ពុជាចូលរួម វេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០

នៅព្រឹកថ្ងៃអង្គារ ទី១៨ ខែមីនា ឆ្នាំ២០២៥ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំវេទិការវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីសម្រេចបានចក្ខុវិស័យឆ្នាំ២០៥០ដែលវេទិកានេះដឹកនាំផ្ទាល់ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមសមាគមឧកញ៉ាកម្ពុជាក៏បានចូលរួមក្នុងវេទិកានេះផងដែរ។

វេទិកានេះក៏មានគោលបំណងរួមគ្នាវាយតម្លៃលើវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីមានមូលដ្ឋានច្បាស់លាស់បន្ថែមទៀតសម្រាប់បន្តពង្រឹងការរៀបចំ និងការអនុវត្តកំណែទម្រង់ឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ គោលនយោបាយអាទិភាពចំនួន៦ និងវិធានការគន្លឹះចំនួន៥របស់រាជរដ្ឋាភិបាលសំដៅសម្រេចចក្ខុវិស័យកម្ពុជាក្នុងការអភិវឌ្ឍប្រទេសឱ្យក្លាយទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ដោយត្រូវរៀបចំរៀងរាល់៣ឆ្នាំម្តង ហើយចាប់ផ្តើមអនុវត្តដំបូងពីឆ្នាំ២០២៤ ក្នុងគោលបំណងវាយតម្លៃអំពីវឌ្ឍនភាព បញ្ហាប្រឈម ដំណោះស្រាយ និងការដាក់ចេញនូវការតម្រង់ទិសផ្នែកគោលនយោបាយសម្រាប់សម្រួចការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីចូលរួមកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។








សូមបញ្ជាក់ថា ដំណើរការរៀបចំវេទិកានេះត្រូវអនុវត្តទៅតាមជំហានសំខាន់ៗចំនួន ៣រួមមាន៖

- **ជំហានទី១៖** ការរៀបចំវេទិកានៅថ្នាក់ក្រោមជាតិដែលជំហាននេះត្រូវរៀបចំនៅថ្នាក់ឃុំ សង្កាត់ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងនៅថ្នាក់រាជធានី ខេត្តនីមួយៗ។
- **ជំហានទី២៖** ការរៀបចំកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនានានៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងការរៀបចំកិច្ចប្រជុំ គ.ជ.អ.ប.។
- **ជំហានទី៣៖** ការរៀបចំវេទិការវាងរាជរដ្ឋាភិបាលនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបាននិងកំពុងប្រព្រឹត្តទៅយ៉ាងអធិកអធមនាពេលនេះ។

ក្នុងជំហាននីមួយៗផ្តោតលើការពិនិត្យ និងពិភាក្សាលើប្រធានបទសំខាន់ៗចំនួន៧ ដែលពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន៖

- **ទី១៖** ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីការងារ
- **ទី២៖** ស្ថានភាពនៃការផ្ទេរ និងការអនុវត្តមុខងារ
- **ទី៣៖** ស្ថានភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស
- **ទី៤៖** ការគ្រប់គ្រង ការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ
- **ទី៥៖** ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាពផ្ទៃក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយស្ថាប័នថ្នាក់ជាតិ និងជាមួយប្រជាពលរដ្ឋ
- **ទី៦៖** ការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋាន
- **ទី៧៖** ការគាំទ្រ តាមដាន ត្រួតពិនិត្យ វាយតម្លៃ ការធ្វើអធិការកិច្ច និងសវនកម្ម។









# អ្នកឧកញ៉ា ផៃ ហុកឈួន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌន នៃសាសនាឥស្លាមកម្ពុជា លើកទី៩ ឆ្នាំ២០២៥

នាល្ងាចថ្ងៃចន្ទ ទី២៤ ខែមីនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ផៃ ហុកឈួន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបចូលរួមក្នុងពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌន នៃសាសនាឥស្លាមកម្ពុជា លើកទី៩ ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

**សម្តេច** បានថ្លែងថា ការស្រាយបួសជាក្រឹត្យក្រមច្បាប់សាសនាឥស្លាម ដែលសាសនិកខ្មែរឥស្លាមទាំងនៅកម្ពុជានិងនៅទូទាំងសកលលោកសុទ្ធតែធ្វើការប្រតិបត្តិដូចគ្នា ហើយនៅពេលផ្តើមចូលខែរ៉ាម៉ាឌន **សម្តេច** ក៏បានផ្ញើសារជូនពរសាសនិកឥស្លាមកម្ពុជា និងសាសនិកឥស្លាមនៅទូទាំងពិភពលោក និងជូនពរនៅពេលបញ្ចប់ខែរ៉ាម៉ាឌនដោយជោគជ័យដែលអនុវត្តតាមគន្លងដ៏ល្អប្រពៃរបស់ **សម្តេចតេជោ**។

**សម្តេច** បានបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាតែងតែយកចិត្តទុកដាក់ និងផ្តល់សេរីភាពជំនឿសាសនាយ៉ាងទូលំទូលាយដល់ប្រជាជនទូទៅដែលឈរលើមូលដ្ឋាននៃការពង្រឹងសុខដុមនីយកម្មសាសនិក នៃគ្រប់និកាយសាសនាហើយប្រឆាំងនូវរាល់ទង្វើរើសអើងសំដៅទប់ស្កាត់ការយកសាសនាទៅធ្វើអាជីវកម្មដែលអាចបង្ករិបត្តិសាសនានៅកម្ពុជា។









**សម្តេច** បានបន្ថែមថា កម្ពុជាពិតជាមានមោទនភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួនដែលគោរពកាន់សាសនាផ្សេងៗគ្នា ប៉ុន្តែមានសាមគ្គីគ្នាយ៉ាងល្អ មិនត្រឹមតែជាមោទនភាពសម្រាប់កម្ពុជានោះទេ តែក៏ជាមោទនភាពសម្រាប់ប្រទេសនៅក្នុងតំបន់ និងពិភពលោកផងដែរ ដែលប្រទេសជាច្រើនកោតសសើរចំពោះសុខដុមនីយកម្មសាសនានៅកម្ពុជា តាមរយៈគោលនយោបាយដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលដែលមានកិច្ចសហការល្អជាមួយគ្រប់ស្ថាប័ន អង្គភាព ក៏ដូចជា ដៃគូពាក់ព័ន្ធដើម្បីធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់លើការងារ និងបង្កភាពងាយស្រួលជូនប្រជាពលរដ្ឋគ្រប់សាសនិកនៅកម្ពុជាទាំងបច្ចុប្បន្ន និងទៅអនាគត។

សូមបញ្ជាក់ថា កាតព្វកិច្ចបួសខែរ៉ាម៉ាឌន គឺជាសសរស្តម្ភទី៤ នៃសាសនាឥស្លាមក្នុងចំណោមសសរស្តម្ភទាំង៥ ។ ខែរ៉ាម៉ាឌន គឺជាខែទី៩ និងត្រូវបានប្រសិទ្ធនាមជាខែដ៏ពិសិដ្ឋនៃសាសនាឥស្លាមផងដែរ ដែលជាខែជំរុញឱ្យជនម៉ូស្លីមទាំងឡាយខិតខំប្រឹងប្រែងប្រព្រឹត្តអំពើល្អឱ្យបានកាន់តែច្រើន ពិសេសគឺជួយដល់អ្នកក្រខ្សត់ខ្វះលទ្ធភាព។ បន្ថែមពីនេះ មូលហេតុសំខាន់ចម្បងមួយទៀត ក្រៅការបួស ឬតមអាហារអំណត់នាពេលថ្ងៃ សាសនាឥស្លាមក៏បានជំរុញ និងលើកទឹកចិត្តដល់សាសនិកទាំងអស់ក្នុងការសូត្រគម្ពីរអាល់គួរអានឱ្យបានច្រើនផងដែរ ព្រោះថាខែរ៉ាម៉ាឌន គឺជាខែដែលអល់ឡោះបានបញ្ចុះគម្ពីរអាល់គួរអានជាលើកដំបូងតាមរយៈព្យាការីម៉ូហាំម៉ាត់ដើម្បីផ្សព្វផ្សាយដល់ជនម៉ូស្លីមទាំងអស់។















# សមាគមឧកញ៉ាកម្ពុជា រៀបចំពិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ ប្រចាំឆ្នាំ២០២៥ ក្រោមប្រធានបទ "ទាំងអស់គ្នាដើម្បីការអប់រំ" នៅសាលាចំនួន ៩ ក្នុងខេត្តកំពង់ធំ











ដោយទទួលបានការចាត់តាំងពី លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា នាថ្ងៃទី២៥ និង២៦ ខែមីនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូបទៀត ជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា និងក្រុមការងារ នៃអគ្គលេខាធិការដ្ឋានបាននាំយកអំណោយជូនដល់សាលាចំនួន ៩ ដែលស្ថិតនៅក្នុងខេត្តកំពង់ធំ។

កម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរិសធម៌ប្រចាំឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជាក្រោមប្រធានបទ "ទាំងអស់ គ្នាដើម្បីការអប់រំ" នេះ ក៏មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម នួន ផារ័ត្ន អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ, ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ធំដែលរួមមានឯកឧត្តម ស ចាន់ធី, ឯកឧត្តម ទិត សុធា និងឯកឧត្តម សេង សាវន ព្រមទាំងអាជ្ញាធរដែនដី និងមន្ត្រីរាជការមកពីស្ថាប័នពាក់ព័ន្ធជាច្រើនទៀត។

នៅក្នុងកម្មវិធីដែលមានរយៈពេល ២ថ្ងៃពេញនេះ បានប្រារព្ធឡើងនៅក្នុងបរិវេណសាលាចំនួន ៩ នៅទូទាំងខេត្តកំពង់ធំ ដោយ អ្នកឧកញ៉ា ហ៊ុន ឡាក់ បាននាំយកនូវអំណោយរួមមាន ថវិកាសម្រាប់ជួសជុលអគារសិក្សា ឬហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្តាសាលាមួយចំនួន ក៏ដូចជាសម្ភារៈសិក្សា សម្លៀកបំពាក់ ម៉ូតូ កង់ និងថវិកាជូនចំពោះលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៃសាលាទាំង ៩ ដែលរួមមានចំនួនសរុបជាង ៣ពាន់នាក់។

សូមបញ្ជាក់ដែរថា ក្នុងចំណោមសាលាទាំង ១០ មានតែវិទ្យាល័យទ្រៀលប៉ុណ្ណោះដែលបានប្រារព្ធពិធីប្រគល់ និងទទួលអំណោយរួចរាល់ហើយកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ព្រមទាំង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ និងលោកជំទាវ ដោយសាលានេះទទួលបានអគារសិក្សាថ្មីចំនួន ១ខ្នង កម្ពស់ ៣ជាន់ ស្មើនឹង ៣០បន្ទប់ រួមទាំងអំណោយជាសម្ភារៈសិក្សា ម៉ូតូ កង់ និងថវិកាសម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សសរុបជាង ២ពាន់នាក់ផងដែរ។

## កម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ ប្រចាំឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជាក្រោមប្រធានបទ "ទាំងអស់គ្នាដើម្បីការអប់រំ" នៅសាលាបឋមសិក្សា សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ តាំងគោក ខេត្តកំពង់ធំ

នៅព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជារួមជាមួយ ឧកញ៉ាបណ្ឌិត លី រិទ្ធ និងឧកញ៉ា លន់ ពៅ សមាជិកសមាគមឧកញ៉ាកម្ពុជា បានចូលរួមក្នុងកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរិសធម៌ ប្រចាំឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា ជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៅសាលាបឋមសិក្សា សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ តាំងគោក ដែលស្ថិតនៅភូមិតាំងគោក ឃុំសូយោង ស្រុកតាំងគោក ខេត្តកំពង់ធំ។

ក្នុងឱកាសនេះដែរ ក៏មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម ស ចាន់ធី រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ធំ ព្រមទាំងវត្តមានរបស់លោក លោកស្រី ជាអាជ្ញាធរមូលដ្ឋាន កងកម្លាំងមានសមត្ថកិច្ច និងមន្ត្រី នៃស្ថាប័នពាក់ព័ន្ធជាច្រើនរូបទៀតផងដែរ។ ជាមួយគ្នានេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានពាំនាំនូវបណ្តាំផ្ញើសួរសុខទុក្ខពីសំណាក់លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ជូនចំពោះលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស អមដោយសារជូនពរ និងលើកទឹកចិត្តឱ្យក្មួយៗខិតខំប្រឹងប្រែងរៀនសូត្រ ដើម្បីក្លាយជាកូនល្អនៅក្នុងគ្រួសារ សិស្សល្អនៅក្នុងសាលា និងជាពលរដ្ឋល្អនៅក្នុងសង្គមជាតិ។

អ្នកឧកញ៉ាអគ្គលេខាធិការ បានបន្ថែមថា អំណោយដែលបានផ្តល់ជូននៅថ្ងៃនេះគឺបានកើតចេញពីការចូលរួមប្រកបដោយសាមគ្គីភាព របស់សមាជិក នៃសមាគមឧកញ៉ាកម្ពុជា ស្របទៅតាមទស្សនវិស័យក្នុងការបំពេញសកម្មភាពមនុស្សធម៌ ព្រមគ្នានឹងសកម្មភាពធុរកិច្ច ដែលត្រូវបានកំណត់ជាបេសកកម្មអាទិភាពរបស់សមាគមឧកញ៉ាកម្ពុជា។












ទន្ទឹមនឹងនេះ ឯកឧត្តម ស ចាន់ធី បានមានប្រសាសន៍ថា ក្នុងនាមឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ ឯកឧត្តមពិតជាមានក្តីរីករាយ ក្រៃលែង និងសូមថ្លែងអំណរគុណចំពោះសមាគមឧកញ៉ាកម្ពុជាដែលបានកៀរគរនូវថវិកា សម្ភារៈសិក្សា សម្ភារៈការិយាល័យ សម្លៀកបំពាក់ និងមធ្យោបាយធ្វើដំណើរដែលអំណោយទាំងនេះពិតជាមានសារៈសំខាន់ និងអាចជួយសម្រួលដល់ជីវភាពបានមួយផ្នែកផងដែរ។

សូមបញ្ជាក់ថា សាលាបឋមសិក្សាសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ តាំងគោក គឺជាសាលាមួយក្នុងសាលាទាំង ១០នៅក្នុងខេត្តកំពង់ធំ ដែលទទួលបានអំណោយពីសមាគមឧកញ៉ាកម្ពុជា ដោយសាលានេះទទួលបាននូវ៖

១. ក្តារខៀន១៦ តុកៅអី៦៥ កុំព្យូទ័រ១ ម៉ាស៊ីនព្រីនឯកសារ១ និងម៉ាស៊ីនបញ្ចាំងឯកសារ១

២. គ្រូបង្រៀនសរុបចំនួន ១៨នាក់ ដែលម្នាក់ៗទទួលបាន កញ្ចប់សម្លៀកបំពាក់ចម្រុះ ១កញ្ចប់ មាន (កាតាប១, អាវយឺតហេរ៉ូ១ និង អាវស្រ្តី១) និងថវិកា ៦ម៉ឺនរៀល

៣. សិស្សានុសិស្សសរុបចំនួន ៦៤៤នាក់ ដែលម្នាក់ៗទទួលបាន សម្ភារៈសិក្សា ១ឈុត មាន (កាតាប១, សៀវភៅ១០ក្បាល, ប៊ិច ខៀវ៥ដើម, ប៊ិចក្រហម៥ដើម, ខ្មៅដៃ១០ដើម, ទឹកលុប២ដើម, ជ័រលុប២ដុំ, ប្រដាប់ខួង២ដុំ, បន្ទាត់១ដើម, និងកាបូបប៊ិច១), ឯកសណ្ឋាន សិស្ស ១ឈុត មាន (ខោ ឬសំពត់១, អាវស១), សម្លៀកបំពាក់នៅផ្ទះ ១ឈុត មាន (អាវយឺតនិងខោ ឬរ៉ូបចម្រុះពណ៌២, អាវហេរ៉ូ១) និងថវិកា ៤ម៉ឺនរៀល

៤. សិស្សានុសិស្សចំនួន ៥៤នាក់ដែលខ្វះមធ្យោបាយធ្វើដំណើរ ទទួលបានកង់ម្នាក់១គ្រឿង សរុប៥៤គ្រឿង។











## សមាគមឧកញ៉ាកម្ពុជា បន្តនាំយកអំណោយសប្បុរសធម៌ប្រគល់ជូនលោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្ស ជិត ៦០០នាក់នៅសាលាបឋមសិក្សាបារាយណ៍ ខេត្តកំពង់ធំ

ដោយទទួលបានការណែនាំពីលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា នាព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ រួមជាមួយឧកញ៉ា លី រិទ្ធ និងឧកញ៉ា លន់ ពៅ ដែលជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានបន្តចូលរួមក្នុងកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ប្រចាំឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា ជូនដល់លោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្សនៅសាលាបឋមសិក្សាបារាយណ៍ដែលស្ថិតនៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ។

កម្មវិធីនេះ ក៏មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម ញឹក បានខេង អភិបាលរងខេត្តកំពង់ធំ និងជាតំណាងឯកឧត្តម នួន ផារ័ត្ន អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ។

ក្នុងឱកាសនេះដែរ ឯកឧត្តម ញឹក បានខេង បានថ្លែងថា ខេត្តកំពង់ធំ មានភ័ព្វសំណាងណាស់ដែលទទួលបានអំណោយសរុបប្រមាណជាង ១លានដុល្លាអាម៉េរិកដើម្បីកសាងអគារសិក្សា រួមជាមួយអំណោយជាសម្ភារៈសិក្សា សម្លៀកបំពាក់ និងថវិកាផងដែរ។

ជាមួយគ្នានេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានបញ្ជាក់ថា អំណោយទាំងអស់នេះបានកើតចេញពីស្មារតីសាមគ្គី នៃគ្រួសារសមាគមឧកញ៉ាកម្ពុជា ដែលសមាជិកទាំងអស់បានចូលរួមយ៉ាងសស្រាក់សស្រាំក្នុងសកម្មភាពសប្បុរសធម៌ស្របទៅតាមចក្ខុវិស័យ និងបេសកកម្មរបស់សមាគមដើម្បីជាគុណប្រយោជន៍ដល់សង្គមជាតិ បន្ថែមពីលើសកម្មភាពធុរកិច្ចក្នុងគោលបំណងបង្កើតការងារជូនប្រជាពលរដ្ឋខ្មែរ និងជំរុញកំណើនសេដ្ឋកិច្ចជាតិផងដែរនោះ។

សូមបញ្ជាក់ថា សម្រាប់សាលាបឋមសិក្សាបារាយណ៍ ទទួលបាននូវអំណោយដូចខាងក្រោមនេះ៖

១- គ្រូបង្រៀនចំនួន ១៦នាក់ ម្នាក់ៗទទួលបាន កញ្ចប់សម្លៀកបំពាក់ចម្រុះ ១កញ្ចប់ និងវិកា ៦ម៉ឺនរៀល

២- ចំពោះអ្នកគ្រូបង្រៀនម្នាក់ដែលជួបបញ្ហាកង្វះមធ្យោបាយធ្វើដំណើរទទួលបានម៉ូតូ ១គ្រឿងផងដែរ

៣- សិស្សានុសិស្សចំនួន ៥៦៩នាក់ ម្នាក់ៗទទួលបាន សម្ភារៈសិក្សា ១ឈុត (កាតាប១, សៀវភៅ១០ក្បាល, ប៊ិចខៀវ៥ដើម, ប៊ិចក្រហម៥ដើម, ខ្មៅដៃ១០ដើម, ទឹកលុប២ដើម, ជ័រលុប២ដុំ, ប្រដាប់ខួង២ដុំ, បន្ទាត់១ដើម, និងកាបូបប៊ិច១), ឯកសណ្ឋានសិស្ស ១ឈុត, សម្លៀកបំពាក់នៅផ្ទះ ១ឈុត និងថវិកា ៤ម៉ឺនរៀល

៤. សម្រាប់សិស្សានុសិស្ស ២០នាក់ ដែលមានជីវភាពលំបាកទទួលបានកង់ម្នាក់១គ្រឿង សរុប២០គ្រឿងផងដែរ។



















# លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងសាលាបឋមសិក្សាស្វាយកាល់ មានក្ដីរីករាយក្រៃលែង ក្រោយទទួលបានថវិកាសម្រាប់កសាងផ្លូវបេតុង សម្ភារៈសិក្សា សម្លៀកបំពាក់ មធ្យោបាយធ្វើដំណើរ ព្រមទាំងថវិកាពីសមាគមឧកញ៉ាកម្ពុជា

អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយឧកញ៉ាបណ្ឌិត លី រិទ្ធ និងឧកញ៉ា លន់ ពៅ ដែលជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានបន្ដចូលរួមក្នុងកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរិសធម៌ ប្រចាំឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា ជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅសាលាបឋមសិក្សាស្វាយកាល់ ដែលស្ថិតនៅក្នុងឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។ ក្នុងឱកាសនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានពាំនាំនូវបណ្ដាំផ្ញើសួរសុខទុក្ខពីសំណាក់លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ជូនចំពោះលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ក៏ដូចជាអង្គពិធីទាំង មូលអមដោយសារជូនពរ និងលើកទឹកចិត្តឱ្យក្មួយៗខិតខំប្រឹងប្រែងរៀនសូត្រដើម្បីក្លាយជាកូនល្អនៅក្នុងគ្រួសារ សិស្សល្អនៅក្នុងសាលា និងជាពលរដ្ឋល្អនៅក្នុងសង្គមជាតិ។

សូមបញ្ជាក់ថាសាលាបឋមសិក្សាស្វាយកាល់គឺជាសាលាទី៥ នៅក្នុងខេត្តកំពង់ធំដែលទទួលបាននូវជំនួយជាថវិកា និងអំណោយជាសម្ភារៈនានាពីសមាគមឧកញ៉ាកម្ពុជាដែលក្នុងនោះមានដូចជា៖

១- កញ្ចប់ថវិកាកសាងផ្លូវចាក់បេតុងមួយខ្សែប្រវែង៨៧ម៉ែត្រ ដែលមានចំនួនទឹកប្រាក់ ១៣,៨០០ដុល្លារអាម៉េរិក និងឧបករណ៍បំពងសំឡេង១ឈុត

២- គ្រូបង្រៀនចំនួនទាំងអស់ចំនួន ១៤នាក់ ម្នាក់ៗទទួលបានកញ្ចប់សម្លៀកបំពាក់ចម្រុះ ១កញ្ចប់ និងថវិកា ៦ម៉ឺនរៀល

៣- ចំពោះលោកគ្រូម្នាក់ដែលមានទីតាំងនៅឆ្ងាយពីសាលា និងខ្វះមធ្យោបាយធ្វើដំណើរទទួលបានម៉ូតូ១គ្រឿងផងដែរ

៤- សម្រាប់សិស្សានុសិស្សសរុបចំនួន ៤៥៧នាក់ ម្នាក់ៗទទួលបានសម្ភារៈសិក្សា ១ឈុត, ឯកសណ្ឋានសិស្ស ១ឈុត, សម្លៀកបំពាក់នៅផ្ទះ ១ឈុត និងថវិកា ៤ម៉ឺនរៀល

៥-ជាមួយគ្នានេះ សិស្សានុសិស្សចំនួន ១២០នាក់ដែលមានជីវភាពលំបាក និងមានផ្ទះនៅឆ្ងាយពីសាលាត្រូវទទួលបានកង់ម្នាក់១គ្រឿង សរុប១២០គ្រឿងផងដែរ។























# លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សជាង ៧០០នាក់ក្នុងសាលាបឋមសិក្សាកោះ ទទួលបានអំណោយជា អគារសិក្សា ១ខ្នង កម្ពស់២ជាន់ មាន១០បន្ទប់ សម្ភារៈការិយាល័យ សម្ភារៈសិក្សា ម៉ូតូ កង់ សម្លៀកបំពាក់ និង ថវិកា ពីសមាគមឧកញ៉ាកម្ពុជា

អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយឧកញ៉ា លី រិទ្ធ និងឧកញ៉ា លន់ ពៅ ដែលជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានបន្តចូលរួមក្នុងកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ប្រចាំឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា ជូនដល់លោកគ្រូ  អ្នកគ្រូ និងសិស្សានុសិស្សនៅសាលាបឋមសិក្សាកោះ ដែលស្ថិត នៅក្នុងឃុំកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

សូមបញ្ជាក់ថា សាលាបឋមសិក្សាកោះ គឺជាសាលាទី៦ នៅក្នុងខេត្តកំពង់ធំដែលទទួលបាននូវជំនួយជាថវិកា និងអំណោយជាសម្ភារៈនានាពីសមាគមឧកញ៉ាកម្ពុជាដែលក្នុងនោះមានដូចជា៖

១- អគារសិក្សា ១ខ្នង កម្ពស់ ២ជាន់ មាន ១០បន្ទប់

២- តុកៅអី៥០ កុំព្យូទ័រ១ ទូដាក់ឯកសារ៣ និងកង្ហារ១៥

៣- គ្រូបង្រៀនសរុបចំនួន ១៩នាក់ ដោយម្នាក់ៗទទួលបានកញ្ចប់សម្លៀកបំពាក់ចម្រុះ ១ និងថវិកា ៦ម៉ឺនរៀល

៤- ចំពោះគ្រូបង្រៀន ៤នាក់ដែលជួបបញ្ហាខ្វះមធ្យោបាយធ្វើដំណើរទទួលបានម៉ូតូ ម្នាក់១គ្រឿង សរុប៤គ្រឿង

៥-សិស្សានុសិស្សសរុបមានចំនួន៦៩៥នាក់ម្នាក់ៗទទួលបាន សម្ភារៈសិក្សា ១ឈុត,ឯកសណ្ឋានសិស្ស ១ឈុត,សម្លៀកបំពាក់នៅផ្ទះ ១ឈុត និងថវិកា ៤ម៉ឺនរៀល

៦- សម្រាប់សិស្សានុសិស្សចំនួន ៣៥នាក់ដែលមានផ្ទះនៅឆ្ងាយទទួលបានកង់ម្នាក់១គ្រឿង សរុប៣៥គ្រឿងផងដែរ។



























កម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ ប្រចាំឆ្នាំ២០២៥
របស់សមាគមឧកញ៉ាកម្ពុជា ក្រោមប្រធានបទ «ទាំងអស់គ្នាដើម្បីការអប់រំ»
សាលាបឋមសិក្សាកោះ ភូមិសំណាក ឃុំកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ
ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៥
សមាគមឧកញ៉ាកម្ពុជា



## ឯកឧត្តម នួន ផារ័ត្ន ៖
## "អំណោយរបស់សមាគមឧកញ៉ាកម្ពុជាពិតជាមានតម្លៃខ្លាំងណាស់ សម្រាប់ការលើកស្ទួយវិស័យអប់រំនៅខេត្តកំពង់ធំ"

ក្នុងឱកាសដែលឯកឧត្តមបានអញ្ជើញជាអធិបតីក្នុងកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ប្រចាំឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា ក្រោមប្រធានបទ "ទាំងអស់គ្នាដើម្បីការអប់រំ" នៅសាលាបឋមសិក្សាក្រចាប់ ដែលស្ថិតនៅក្នុងក្រុងស្ទឹងសែននាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ ឯកឧត្តម នួន ផារ័ត្ន អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ បានមានប្រសាសន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជនសមាគមឧកញ៉ាកម្ពុជាទាំងអស់ដែលបានចូលរួមបរិច្ចាគជាថវិកា និងសម្ភារៈតាមរយៈឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ធំ ដោយឯកឧត្តមបានបញ្ជាក់ថាថវិកាទាំងអស់នេះពិតជាមានតម្លៃខ្លាំងណាស់សម្រាប់លើកស្ទួយវិស័យអប់រំនៅខេត្តកំពង់ធំក្នុងការកសាងធនធានមនុស្សប្រកបដោយគុណភាព គុណតម្លៃ អភិវឌ្ឍន៍ប្រទេសជាតិមានការរីកចម្រើនបានឆាប់រហ័ស។

ជាមួយគ្នានោះ ឯកឧត្តម នួន ផារ័ត្ន ក៏បានផ្តាំផ្ញើដល់ក្មួយៗសិស្សានុសិស្សទាំងអស់ឱ្យខិតខំប្រឹងប្រែងរៀនសូត្រដើម្បីអនាគតភ្លឺស្វាងសម្រាប់ខ្លួនឯង គ្រួសារនិងសង្គមជាតិ ពោលគឺត្រូវធ្វើជាសិស្សល្អ ពលរដ្ឋល្អ យុវជនល្អ និងមានសុខភាពល្អដែលជាធនធានមនុស្សដ៏មានគុណតម្លៃ ជាពិសេសត្រូវជៀសឱ្យឆ្ងាយពីគ្រឿងញៀន និងអំពើអបាយមុខទាំងអស់ដើម្បីក្លាយជាយុវជនបន្តវេនប្រកបដោយថាមពលក្នុងការចូលរួមថែរក្សាឱ្យខាងតែបាននូវសុខសន្តិភាព និងការឯកភាពជាតិ។

ក្នុងឱកាសនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគម ឧកញ៉ាកម្ពុជា បានសង្កត់ធ្ងន់ថា ក្រោមការដឹកនាំរបស់លោកអ្នកឧកញ៉ា លី យ៉ុងផាត់ សមាគមឧកញ៉ាកម្ពុជាបានយកចិត្តទុកដាក់ និងចូលរួមយ៉ាងសកម្មក្នុងបេសកកម្មមនុស្សធម៌ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាស្ថាប័នសប្បុរសធម៌ផ្សេងៗទៀតរួមមានកាកបាទក្រហមកម្ពុជា មន្ទីរពេទ្យ វត្តអារាម និងជាពិសេសលើវិស័យអប់រំដែលជាការវិនិយោគមិនចេះរីងស្ងួតសំដៅបង្កើនធនធានមនុស្សសម្រាប់សង្គមជាតិ។

អ្នកឧកញ៉ា បានបន្ថែមថា អំណោយទាំងអស់នេះបានបង្ហាញពីស្មារតីសាមគ្គី នៃគ្រួសារសមាគមឧកញ៉ាកម្ពុជាដែលបានចូលរួមយ៉ាងសស្រាក់សស្រាំក្នុងសកម្មភាពសប្បុរសធម៌ស្របទៅតាមចក្ខុវិស័យ និងបេសកកម្មរបស់សមាគមដើម្បីជាគុណប្រយោជន៍ដល់សង្គមជាតិ បន្ថែមពីលើសកម្មភាពធុរកិច្ចក្នុងគោលបំណងបង្កើតការងារជូនប្រជាពលរដ្ឋខ្មែរ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។

ក្នុងដំណើរបំពេញការងារមនុស្សធម៌នេះដែរក៏មានវត្តមានចូលរួមរបស់អ្នកឧកញ៉ា ហេង បូរិន, ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណារ័ត្ន, ឧកញ៉ាបណ្ឌិត ជា ដាណា និងឧកញ៉ាបណ្ឌិត លី រិទ្ធ ដែលជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា។



សូមបញ្ជាក់ថា     សាលាបឋមសិក្សាក្រចាប់  គឺជាសាលាមួយក្នុងសាលាទាំង  ១០នៅក្នុងខេត្តកំពង់ធំដែលទទួលបានអំណោយពីសមាគមឧកញ៉ាកម្ពុជា ដោយសាលានេះទទួលបាននូវការឧបត្ថម្ភដូចខាងក្រោម៖

១- គ្រូបង្រៀន ១០នាក់ ដែលម្នាក់ៗទទួលបាន កញ្ចប់សម្លៀកបំពាក់ចម្រុះ ១កញ្ចប់ និងថវិកា ៦ម៉ឺនរៀល។

២-សិស្សានុសិស្ស១៧៧នាក់ម្នាក់ៗទទួលបានសម្ភារៈសិក្សា១ឈុត(កាតាប១,សៀវភៅ១០ក្បាល,ប៊ិចខៀវ៥ដើម,ប៊ិចក្រហម៥ដើម, ខ្មៅដៃ១០ដើម, ទឹកលុប២ដើម, ជ័រលុប២ដុំ, ប្រដាប់ខួង២ដុំ, បន្ទាត់១ដើម, និងកាបូបប៊ិច១), ឯកសណ្ឋានសិស្ស ១ឈុត, សម្លៀកបំពាក់នៅផ្ទះ ១ឈុត និងចំនួនថវិកា ៤ម៉ឺនរៀល។ ជាមួយគ្នានេះ សិស្សានុសិស្ស ២០នាក់ ដែលខ្វះមធ្យោបាយធ្វើដំណើរទទួលបានកង់ម្នាក់១គ្រឿង សរុប២០គ្រឿងផងដែរ។










# សាលាបឋមសិក្សាអូរសំបួរ ទទួលបានអំណោយជា អគារសិក្សា ១ខ្នង មាន ៥បន្ទប់ ខ្លោងទ្វារថ្មី ម៉ូតូ កង់ សម្ភារៈសិក្សា សម្លៀកបំពាក់ និងថវិកា ពីសមាគមឧកញ៉ាកម្ពុជា

ដោយទទួលបានការណែនាំពីលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ចូលរួមអមដំណើរដោយ ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណរ័ត្ន, ឧកញ៉ាបណ្ឌិត ជា ដាណា, អ្នកឧកញ៉ា ហេង បូរិន, ឧកញ៉ាបណ្ឌិត លី រិទ្ធ, និងឧកញ៉ា វ៉ាន់ សឿន បានបន្តចូលរួមក្នុងកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ប្រចាំឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា ជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅសាលាបឋមសិក្សាអូរសំបួរ ដែលស្ថិតនៅក្នុង ឃុំក្ដីដូង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

ក្នុងឱកាសនេះដែរ ក៏មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម ទិត សុធា រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកកំពង់ស្វាយ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ធំ។

សូមបញ្ជាក់ថា សាលាបឋមសិក្សាអូរសំបួរ គឺជាសាលាទី៧ នៅក្នុងខេត្តកំពង់ធំដែលទទួលបាននូវជំនួយជាថវិកា និងអំណោយជាសម្ភារៈនានាពីសមាគមឧកញ៉ាកម្ពុជាដែលក្នុងនោះមានដូចជា៖

១- អគារសិក្សា ១ខ្នង កម្ពស់ ១ជាន់ មាន ៥បន្ទប់

២- កញ្ចប់ថវិកាកសាងខ្លោងទ្វារ១ ដែលមានទឹកប្រាក់ចំនួន ១៤,៥១៩ដុល្លារអាម៉េរិក ហើយនឹងដាក់ឈ្មោះថា "សាលាបឋមសិក្សាសមាគមឧកញ៉ាកម្ពុជា អូរសំបួរ"

៣- គ្រូបង្រៀនចំនួន ៦នាក់ ម្នាក់ៗទទួលបានកញ្ចប់សម្លៀកបំពាក់ចម្រុះ ១កញ្ចប់ និងថវិកា ៦ម៉ឺនរៀល

៤- ចំពោះលោកគ្រូបង្រៀន១នាក់ ដែលខ្វះមធ្យោបាយធ្វើដំណើរទទួលបានម៉ូតូ ១គ្រឿង

៥- សិស្សានុសិស្សសរុបចំនួន ១៤០នាក់ ម្នាក់ៗទទួលបានសម្ភារៈសិក្សា ១ឈុត, ឯកសណ្ឋានសិស្ស ១ឈុត, សម្លៀកបំពាក់នៅផ្ទះ ១ឈុត និងថវិកា ៤ម៉ឺនរៀល

៦- សម្រាប់សិស្សានុសិស្សចំនួន ១៣៨នាក់ដែលមានការលំបាកក្នុងជីវភាពទទួលបានកង់ម្នាក់១គ្រឿង សរុប១៣៨គ្រឿងផងដែរ។



























# សាលាបឋមសិក្សាហ៊ុន សែន ឈូកជីព្រះ ទទួលបានអំណោយជា អគារសិក្សា ១ខ្នង មាន ៥បន្ទប់ កង់ សម្ភារៈ សិក្សា សម្លៀកបំពាក់ និងថវិកា ពីសមាគមឧកញ៉ាកម្ពុជា

ដោយទទួលបានការណែនាំពីលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ចូលរួមអមដំណើរដោយ ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណរ័ត្ន, ឧកញ៉ាបណ្ឌិត ជា ដាណា, អ្នកឧកញ៉ា ហេង បូរិន, ឧកញ៉ាបណ្ឌិត លី រិទ្ធ, និងឧកញ៉ា វ៉ាន់ សឿន បានបន្តចូលរួមក្នុងកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ប្រចាំឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា ជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅសាលាបឋមសិក្សាហ៊ុន សែន ឈូកជីព្រះ ដែលស្ថិតនៅក្នុងឃុំចំណាក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ។

សូមបញ្ជាក់ថា សាលាបឋមសិក្សាហ៊ុន សែន ឈូកជីព្រះ គឺជាសាលាទី៨ នៅក្នុងខេត្តកំពង់ធំដែលទទួលបាននូវជំនួយជាថវិកា និងអំណោយជាសម្ភារៈនានាពីសមាគមឧកញ៉ាកម្ពុជាដែលក្នុងនោះមានដូចជា៖

១- អគារសិក្សា ១ខ្នង កម្ពស់ ១ជាន់ មាន ៥បន្ទប់

២- គ្រូបង្រៀនសរុបចំនួន ៨នាក់ ម្នាក់ៗទទួលបានកញ្ចប់សម្លៀកបំពាក់ចម្រុះ ១កញ្ចប់, ថវិកា ៦ម៉ឺនរៀល និងកង់ម្នាក់១គ្រឿង សរុប១០គ្រឿងផងដែរ

៣- សិស្សានុសិស្សសរុបមានចំនួន ២៣២នាក់ដែលម្នាក់ៗទទួលបាន សម្ភារៈសិក្សា ១ឈុត, ឯកសណ្ឋានកីឡា ១ឈុត, សម្លៀកបំពាក់នៅផ្ទះ ១ឈុត និងថវិកា ៤ម៉ឺនរៀល។

៤- សម្រាប់សិស្សានុសិស្ស ២៨នាក់ដែលមានជីវភាពលំបាកទទួលបានកង់ម្នាក់១គ្រឿង សរុប២៨គ្រឿង។














កម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ ប្រចាំឆ្នាំ២០២៥
របស់សមាគមឧកញ៉ាកម្ពុជា ក្រោមប្រធានបទ -ទាំងអស់គ្នាដើម្បីការអប់រំ-
សមាគមឧកញ៉ាកម្ពុជា

















# សាលាបឋមសិក្សាត្រពាំងអារក្ស ទទួលបានអំណោយជា កញ្ចប់ថវិកាជួសជុលបន្ទប់រៀន ម៉ូតូ កង់ សម្ភារៈ សិក្សា សម្លៀកបំពាក់ និងថវិកា ពីសមាគមឧកញ៉ាកម្ពុជា

ដោយទទួលបានការណែនាំពីលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា នាព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ចូលរួមអមដំណើរដោយ ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណរ័ត្ន, ឧកញ៉ាបណ្ឌិត ជា ដាណា, អ្នកឧកញ៉ា ហេង បូរិន, ឧកញ៉ាបណ្ឌិត លី រិទ្ធ, និងឧកញ៉ា វ៉ាន់ សឿន បានបន្តចូលរួមក្នុងកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ប្រចាំឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា ជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅសាលាបឋមសិក្សាត្រពាំងអារក្ស ដែលស្ថិតនៅក្នុងឃុំជ័យ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

សូមបញ្ជាក់ថា សាលាបឋមសិក្សាត្រពាំងអារក្ស គឺជាសាលាទី៩ នៅក្នុងខេត្តកំពង់ធំដែលទទួលបាននូវជំនួយជាថវិកា និងអំណោយជាសម្ភារៈនានាពីសមាគមឧកញ៉ាកម្ពុជាដែលក្នុងនោះមានដូចជា៖

១- កញ្ចប់ថវិកាជួសជុលបន្ទប់រៀនចំនួន ១,៦០០ ដុល្លារអាម៉េរិក

២- គ្រូបង្រៀន ៩នាក់ ម្នាក់ៗទទួលបានកញ្ចប់សម្លៀកបំពាក់ចម្រុះ ១កញ្ចប់ និងថវិកា ៦ម៉ឺនរៀល

៣- ចំពោះលោកគ្រូ អ្នកគ្រូ ៦នាក់ដែលមានបញ្ហាកង្វះមធ្យោបាយធ្វើដំណើរទទួលបានម៉ូតូម្នាក់១គ្រឿង សរុប៦គ្រឿងផងដែរ

៤- សិស្សានុសិស្សសរុបចំនួន ២៦១នាក់ ម្នាក់ៗទទួលបានសម្ភារៈសិក្សា ១ឈុត, ឯកសណ្ឋានសិស្ស ១ឈុត, សម្លៀកបំពាក់នៅផ្ទះ ១ឈុត និង ថវិកា ៤ម៉ឺនរៀល

៥- សម្រាប់សិស្សានុសិស្ស៣៧នាក់ដែលមានផ្ទះនៅឆ្ងាយពីសាលារៀនទទួលបានកង់ម្នាក់១គ្រឿង សរុប៣៧គ្រឿងផងដែរ។























## សាលាបឋមសិក្សាជាន់លែង ភូមិថ្មី ទទួលបានអំណោយជា អគារសិក្សាថ្មី១ខ្នង កញ្ចប់ថវិកាជួសជុល បន្ទប់រៀន កង់ សម្ភារៈសិក្សា សម្លៀកបំពាក់ និងថវិកា ពីសមាគមឧកញ៉ាកម្ពុជា

ដោយទទួលបានការណែនាំពីលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា នារសៀលថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥ ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណរ័ត្ន សមាជិកសកម្ម នៃសមាគមឧកញ៉ាកម្ពុជា រួមជាមួយឧកញ៉ាបណ្ឌិត ជា ដាណា និង ឧកញ៉ា វ៉ាន់ សឿន បានបន្តចូលរួមក្នុងកម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ ប្រចាំឆ្នាំ២០២៥របស់សមាគមឧកញ៉ាកម្ពុជា ជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៅសាលាបឋមសិក្សាជាន់លែង ភូមិថ្មី ដែលស្ថិតនៅក្នុងឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។

សូមបញ្ជាក់ថា សាលាបឋមសិក្សាជាន់លែង ភូមិថ្មី គឺជាសាលាទី១០ នៅក្នុងខេត្តកំពង់ធំដែលទទួលបាននូវជំនួយជាថវិកា និងអំណោយជាសម្ភារៈនានាពីសមាគមឧកញ៉ាកម្ពុជាដែលក្នុងនោះមានដូចជា៖

១- អគារសិក្សាថ្មី ១ខ្នង កម្ពស់ ១ជាន់ មាន ៥បន្ទប់

២- កញ្ចប់ជួសជុលអគារសិក្សា ចំនួន ១០,០០៥$

៣- គ្រូបង្រៀនសរុប ១៤នាក់ ម្នាក់ៗទទួលបានកញ្ចប់សម្លៀកបំពាក់ចម្រុះ ១កញ្ចប់ និងថវិកា ៦ម៉ឺនរៀល។ ក្នុងនោះគ្រូបង្រៀន៦នាក់ ទទួលបានកង់ម្នាក់១គ្រឿង សរុប ៦គ្រឿងផងដែរ។

៤- សិស្សានុសិស្សសរុបចំនួន ៤៤០នាក់ ម្នាក់ៗទទួលបាន សម្ភារៈសិក្សា ១ឈុត, ឯកសណ្ឋានសិស្ស ១ឈុត, សម្លៀកបំពាក់នៅផ្ទះ ១ឈុត និងថវិកា ៤ម៉ឺនរៀល

៥- សម្រាប់សិស្សានុសិស្ស ១៧៧នាក់ ទទួលបានកង់ម្នាក់១គ្រឿង សរុប១៧៧គ្រឿងផងដែរ។



























កម្មវិធីសំណេះសំណាល និងចែកអំណោយសប្បុរសធម៌ ប្រចាំឆ្នាំ២០២៥
របស់សមាគមឧកញ៉ាកម្ពុជា ក្រោមប្រធានបទ «ទាំងអស់គ្នាដើម្បីការអប់រំ»
សាលាបឋមសិក្សាផាន់លែង ភូមិថ្មី ភូមិផាន់លែង ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ
ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៥

# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាអញ្ជើញ ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន ដែលត្រូវជាបងប្រុសច្បងរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នារសៀលថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលរួមមានវត្តមានរបស់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ចំនួន ៣៧រូប ជាអនុប្រធាន សមាជិកក្រុមប្រឹក្សាភិបាល ក៏ដូចជាសមាជិក នៃសមាគមឧកញ៉ាកម្ពុជា អញ្ជើញដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ដែលត្រូវជាបងប្រុសច្បងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសសមាគមឧកញ៉ាកម្ពុជា នៅគេហដ្ឋាននៃសព ក្នុងសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

សូមបញ្ជាក់ថា **ឯកឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** បានទទួលអនិច្ចកម្មកាលពីព្រឹកថ្ងៃសុក្រ ១៥រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥នេះ នាវេលាម៉ោង ២:២៧នាទី ក្នុងជន្មាយុ ៧៨ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់ **ឯកឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ** គឺជាការបាត់បង់ឪពុក ឪពុកក្មេក និងជីតា ដែលជាទីគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅនិងពោរពេញដោយព្រហ្មវិហារធម៌ដ៏ល្អប្រពៃ។ មិនត្រឹមតែប៉ុណ្ណោះ **ឯកឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ** គឺជាកុលបុត្រខ្មែរដ៏ឆ្នើមមួយរូបដែលបានបូជាអស់កម្លាំងកាយ ចិត្ត ប្រាជ្ញាស្មារតី ក្នុងពលិកម្មដើម្បីជាតិ សាសនា និងព្រះមហាក្សត្រ។ សកម្មភាពដ៏ឧត្តុង្គឧត្តមនេះ បានធ្វើឱ្យ **ឯកឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** ទទួលបាននូវការគោរពស្រឡាញ់ពីមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ព្រះសង្ឃ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន និងត្រូវបាន **ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជាប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសជាច្រើន ជា ពិសេសគ្រឿងឥស្សរិយយសខ្ពស់បំផុតគឺ «ថ្នាក់ជាតូបការ» និងគោរមងារជា «**អ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន**» នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣។

សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ **ឯកឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។




ពិធីបុណ្យសព
ឯកឧត្តម អ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន
បានទទួលមរណភាពក្នុងជន្មាយុ ៧៨ឆ្នាំ ដោយរោគាពាធ
ថ្ងៃសុក្រ ១៥រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

















# ទទួលបានព័ត៌មានអំពីដៃគូរបស់យើងខ្ញុំតាមរយៈ

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
www.cdc.gov.kh

ទីស្តីការគណៈរដ្ឋមន្ត្រី
www.pressocm.gov.kh

ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី
www.coj.gov.kh

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
www.mfaic.gov.kh

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
www.maff.gov.kh

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
www.mef.gov.kh

ក្រសួងពាណិជ្ជកម្ម
www.moc.gov.kh

## ទំនាក់ទំនងនិងទទួលបានព័ត៌មានអំពីយើងខ្ញុំតាមរយៈ

Website Facebook Telegram Youtube TikTok X(Twitter)


ទីស្នាក់ការ សណ្ឋាគារភ្នំពេញ លេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

(+៨៥៥) ២៣ ៨៦០ ៩៩៩ info@cambodianoknha.org www.cambodianoknha.org